# វិទ្យាស្ថានជាតិអប់រំ

## NATIONAL INSTITUTE OF EDUCATION

# មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

## NEW GENERATION PEDAGOGICAL RESEARCH CENTER


# កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅ
# អនុវិទ្យាល័យមួយ ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម

## Poor Academic Performance in Khmer Reading Skill among SEVENTH Grade Students at One Secondary School at Kampong Siem District, Kampong Cham Province

**សារណាខ្លី**

**សម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ**


**រឹម ស្រីវ៉ៃ**


**ឆ្នាំ ២០២២**

# វិទ្យាស្ថានជាតិអប់រំ

## NATIONAL INSTITUTE OF EDUCATION

# មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី

## NEW GENERATION PEDAGOGICAL RESEARCH CENTER

# កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅ អនុវិទ្យាល័យមួយ ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម

# Poor Academic Performance in Khmer Reading Skill among Seventh Grade Students at One Secondary School at Kampong Siem District, Kampong Cham Province


បេក្ខជន ៖ រឹម ស្រីវ៉ៃ

គ្រូណែនាំ ៖ លោក ជី គីមអ៊ី

គណៈកម្មការការពារសារណា៖ ១. បណ្ឌិតសភាចារ្យ ច័ន្ទ រ័ត្ន

២. បណ្ឌិត ស៊ុន សុម៉ារ៉ា

៣. បណ្ឌិត អាន វ៉ុប្រាថ


ឆ្នូ ២០២២

# មូលន័យសង្ខេប

ការសិក្សានេះធ្វើឡើង ក្នុងគោលបំណងសិក្សាអំពីកត្តាដែលបណ្ដាលឱ្យសិស្សខ្សោយក្នុងការអានភាសាខ្មែរ និងបញ្ហាដែលសិស្សជួបប្រទះនៅការខ្សោយការអានភាសាខ្មែរនេះនៅថ្នាក់ទី៧នៅសាលាអនុវិទ្យាល័យមួយកន្លែង ដែលស្ថិតក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម។ ម្យ៉ាងទៀត ការសិក្សាមួយនេះធ្វើឡើងជាមួយ សិស្សខ្សោយ៦នាក់ និងគ្រូបង្រៀនភាសាខ្មែរ១នាក់ ដែលសរុបទាំងអស់៧នាក់។ ការសិក្សានេះ ធ្វើឡើងតាមវិធីសាស្ត្រគុណវិស័យដោយប្រើនូវទម្រង់បែបពាក់កណ្ដាលការសម្ភាសន៍ (semi-structured interview) ដែលមានសំណួរទាំងអស់ជាសំណួរបើក។ តាមរយៈទិន្នន័យដែលទទួលបាន និងធ្វើការវិភាគរួចមក យើងឃើញថាសមត្ថភាពរបស់សិស្សនៅថ្នាក់ទី៧នៅសាលាអនុវិទ្យាល័យស្រុកនៅមានកម្រិតនៅឡើយ។ ចំពោះកត្តាដែលបានរកឃើញដែលបណ្ដាលឱ្យសិស្សខ្សោយក្នុងការអាន អ្នកស្រាវជ្រាវបានរកឃើញពាកត្តាធំៗ (១). កត្តាសុខភាព ពិបាកក្នុងការផ្ចង់ស្មារតី រយៈពេលក្នុងការផ្ដោតខ្លី មិនមានការចងចាំបានយូរ មានការភ្លេចភ្លាំងច្រើន (២). កត្តាគ្រួសារ ខ្វះការយកចិត្តទុកដាក់ មិនមានការជម្រុញកូនឱ្យមានសិក្សានៅផ្ទះបន្ថែម ចំណេះដឹងរបស់ពួកគាត់ហាក់នូវមានកម្រិតនៅឡើយដែលធ្វើឱ្យពួកគាត់មិនអាចជួយ ឬបង្រៀនកូនបានគ្រប់ជ្រុងជ្រោយ។ (៣). កត្តាបរិយាកាស ដោយការរីករាលដាលនៃកូវីដ១៩ ធ្វើឱ្យសិស្សទទួលបានការសិក្សារៀនសូត្រមិន ពេញលេញ បូករួមទាំងពួកគេខ្សោយមូលដ្ឋានគ្រឹះក្នុងការអានស្រាប់ធ្វើឱ្យលទ្ធផលសិក្សាមានការធ្លាក់ចុះ និងកាន់តែកើនឡើងនៃសិស្សខ្សោយការអានច្រើននៅក្នុងថ្នាក់រៀនមិនមានសម្ភារឱ្យសិស្សគ្រប់គ្រាន់ ដូចជាសៀវភៅសិក្សាផ្សេងៗ រីឯបណ្ណាល័យ សម្រាប់សិស្សមធ្យមសិក្សាមិនមានម៉ោងណាមួយដើម្បីដឹកនាំសិស្សចូលបណ្ណាល័យ បញ្ហាសិស្សខ្សោយតាំងពីបឋម ហើយម៉្យាងវិញទៀតសិស្សមានភាពនឿយណាយក្នុងការសិក្សាដោយមិនមានការតាំងចិត្ត និងជម្រុញពីបរិយាកាសជុំវិញ។ លើសពីនេះទៅទៀត ការស្រាវជ្រាវមួយនេះក៏បានរកឃើញថា សិស្សជួបប្រទះបញ្ហាមួយចំនួនដែលបណ្ដាលមកពីកម្សោយនៃការអាន លទ្ធផលនៃការសិក្សាមិនល្អ ធ្លាក់ មានការខ្មាសអៀន ទទួលរងនូវពាក្យសម្ដីមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ពួកគេ មានចិត្តខ្លាចរអាសាលា ខ្លាចមិត្តភក្តិបង្អាប់ សិស្សលែងចង់មករៀន មានគំនិតបោះបង់ចោលការសិក្សា។

ពាក្យគន្លឹះ៖ ការអាន, កម្សោយការអាន

#Abstract

The purpose of this is study to know the factors that cause students to be weak in reading the Khmer language. The problems that faced by the students on seventh grade at One Secondary School is poor in reading of the Khmer language. This study was conducted with 6 weak students and 1 Khmer language teacher, a total of 7 students. This study was conducted using a qualitative approach using a semi-structured interview with all open-ended questions. From the data obtained and analysis, we can see that the ability of students in the seventh grade at One Secondary School is still limited. Here are the factors that causes students to be weak in reading and the researchers found these three major factors. (1). Health factors: Difficulty in concentration, short attention span, no long-term memory and forgetfulness. (2). Family factors: Lack of attention, lack of motivation for children to study at home, moreover, their knowledge seems to be limited, which makes them unable to help or teach their children from all angles. (3). Atmospheric factors by the spread of covid 19 make students less likely to complete their education, including their weaknesses reading skills are the result in declining and growing outcomes of many illiterate students in the classroom. There are no enough materials for students like textbooks, and the library for high school students does not have any time to lead students into the library. And driven by the surrounding environment. In addition, this research also found that students experience some problems caused by poor in reading, poor in academic results, failing, feeling embarrassed, suffering from some words that hurt them emotionally. Because of that they are afraid to go to school, afraid to make new friends or to socialize other people at their age, humiliating students, and because of these reasons they come up with the idea of dropping out of school.

Keywords: reading, poor reading

# ទិចាររបស់គ្រូដឹកនាំ

ឈ្មោះកម្មវិធី៖ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យ

ឈ្មោះបេក្ខជន៖ រឹម ស្រីរ៉ៃ

ចំណងជើងសារណា៖ កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យមួយក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម

សូមបញ្ជាក់ថាកិច្ចការស្រាវជ្រាវខាងលើសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យគឺត្រូវបានធ្វើដោយបេក្ខជនខាងលើពិតប្រាកដមែន ដោយស្ថិតនៅក្រោមការណែនាំរបស់ខ្ញុំ។ ខ្ញុំបានណែនាំលើចំណុចមួយចំនួនដូចជាការមើលទៅលើបញ្ហាសម្រាប់ស្រាវជ្រាវ ការសំយោគឯកសារពាក់ព័ន្ធ វិធីសាស្ត្រនៃការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការពិភាក្សានៅក្នុងសារណាខ្លីនេះ។

ឈ្មោះគ្រូដឹកនាំ៖ ជី គីមអ៊ី

ហត្ថលេខា៖ ………………………………………..

កាលបរិច្ឆេទ៖ ………………………………………..

# ទិចាររបស់អ្នកស្រាវជ្រាវ

សូមបញ្ជាក់ថា ខ្ញុំជាអ្នកស្រាវជ្រាវ « រឹម ស្រីរ៉ៃ » បានធ្វើការស្រាវជ្រាវលើប្រធានបទ «កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យមួយក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម» សម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ ឯកទេសប្រឹក្សាគរុកោសល្យរបស់មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មីនៃវិទ្យាស្ថានជាតិអប់រំ។ បន្ថែមពីលើនេះ ខ្ញុំក៏សូមបញ្ជាក់ផងដែរថា សារណាខ្លីនេះទាំងមូល ឬផ្នែកខ្លះនៃសារណាខ្លីគឺមិនបានប្រើប្រាស់សម្រាប់បំពេញតម្រូវការ ឬការសិក្សាផ្សេងទៀតនៅសាកលវិទ្យាល័យផ្សេងទៀតឡើយ។

ហត្ថលេខា (បេក្ខជន)៖ ............................................

កាលបរិច្ឆេទ៖ ......................................................

ហត្ថលេខា (គ្រូដឹកនាំ)៖ ............................................

កាលបរិច្ឆេទ៖ ......................................................

# សេចក្តីថ្លែងអំណរគុណ

ដំណើរការនៃការសិក្សាស្រាវជ្រាវមួយនេះ អាចនឹងមិនសម្រេចបានជោគជ័យបើមិនមានការណែនាំ និងជំនួយពីសាស្ត្រាចារ្យដឹកនាំ( Supervisor ) ផ្ទាល់របស់នាងខ្ញុំ រួមទាំងគណៈគ្រប់គ្រង និងលោកគ្រូណែនាំ ( Instructor )នៃមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី មិត្តរួមជំនាន់ ព្រមទាំងគណៈគ្រប់គ្រង លោកគ្រូ/អ្នកគ្រូ និងជាពិសេសគឺ ក្រុមគ្រួសាររបស់នាងខ្ញុំ ។

ជាដំបូង នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យដឹកនាំរបស់នាងខ្ញុំ គឺលោកគ្រូ **ជី គីមអ៊ី** ចំពោះការជំនួយក្នុងការណែនាំ ដឹកនាំផ្លូវ ផ្តល់ជាគំនិតយោបល់ ពិភាក្សា ពិនិត្យ និងកែលម្អនូវរាល់ចំណុចខ្វះខាត រួមទាំងផ្តល់នូវឯកសារពាក់ព័ន្ធ ជាពិសេសផ្តល់នូវការជំរុញ លើកទឹកចិត្តរហូតមក ដោយការយកចិត្តទុកដាក់ និងអត់ធ្មត់ ក្នុងកំឡុងពេលការសិក្សាស្រាវជាវនេះ ។

ជាបន្ទាប់ នាងខ្ញុំសូមថ្លែងអំណរគុណដល់លោកគ្រូឯកឧត្តមបណ្ឌិតសភាចារ្យ **ច័ន្ទ រ័ត្ន** ជាគណៈគ្រប់គ្រងនៃមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី រួមទាំងលោកគ្រូណែនាំជាច្រើនរូបទៀត និងលោកគ្រូ/អ្នកគ្រូណែនាំក្នុងស្រុកនិងក្រៅស្រុក ដែលបានជួយបង្ហាញផ្លូវ និងពិនិត្យមើលការការពារនិក្ខេបបទខ្លីរបស់នាងខ្ញុំ និងបានចោទជាសំណួរ ក៏ដូចជាផ្តល់យោបល់ ដើម្បីជួយស្ថាបនាឱ្យការស្រាវជាវមួយនេះមានការកែលម្អអោយកាន់តែប្រសើរជាងមុន ។

នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងក្រៃលែងចំពោះ គណៈគ្រប់គ្រង់ លោកគ្រូ/អ្នកគ្រូ រួមទាំងសិស្សានុសិស្សនៃសាលាអនុវិទ្យាល័យស្រេក ដែលបានអនុញ្ញាត ចូលរួមនិងជួយ ក្នុងដំណើរការស្រាវជ្រាវនេះ ។ ក្នុងនោះដែរនាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះមិត្តរួមជំនាន់ទាំងអស់ បានជំរុញលើកទឹកចិត្ត ផ្តល់ជាគំនិតយោបល់មួយចំនួន ផ្តល់ជាឯកសារ និងមតិយោបល់ល្អៗ ដើម្បីជាជំនួយក្នុងការសិក្សាស្រាវជ្រាវនេះ ផងដែរ ។

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកគ្រួសារជាទីស្រឡាញ់ ជាពិសេសលោកឪពុកអ្នកម្តាយរបស់នាងខ្ញុំដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ មើលថែ ណែនាំប្រៀនប្រដៅ លើក

ទឹកចិត្ត និងលះបង់ទាំងកម្លាំងកាយចិត្ត ព្រមទាំងផ្តល់ភាពកក់ក្តៅដល់កូន ។ ពិតជាសូមអរគុណយ៉ាងក្រៃលែងដោយរកពាក្យពេចន៍មកប្រៀបពុំបាន នូវក្តីស្រឡាញ់ចំពោះកូន ដើម្បីអោយកូនបានរៀនខ្ពង់ខ្ពស់មានចំណេះដឹង មានការងារមួយច្បាស់លាស់ ដូចអ្នកដ៏ទៃ ។ សូមគោរពជូនពរលោកឪពុក អ្នកម្តាយ ពូមីងយាយតា បងប្អូនមានសុខភាពល្អ សុខសប្បាយ សំណាងល្អ ជួបតែជោគជ័យ ។

ជាចុងបញ្ចប់ នាងខ្ញុំសូមគោរពជូនពរដល់ គណៈគ្រប់គ្រង លោកគ្រូ/អ្នកគ្រូ មិត្តរួមថ្នាក់ នៃមជ្ឈមណ្ឌលស្រាវស្រាវគរុកោសល្យជំនាន់ថ្មី និងគណៈគ្រប់គ្រង លោកគ្រូ/អ្នកគ្រូ សិស្សានុសិស្ស នៃសាលាអនុវិទ្យាល័យ អោយមានសុខភាពល្អ សំណាងល្អ និងជោគជ័យគ្រប់ភារកិច្ច ។

ដោយក្តីគោរពនិងថ្លៃងអំណរអរគុណយ៉ាងខ្ពង់ខ្ពស់ពីនាងខ្ញុំ

រឹម ស្រីវ៉ៃ

# មាតិកា


មូលន័យសង្ខេប ........ iii
Abstract ........ iv
វិចាររបស់គ្រូដឹកនាំ ........ v
វិចាររបស់អ្នកស្រាវជ្រាវ ........ vi
សេចក្តីថ្លែងអំណរគុណ ........ vii
មាតិកា ........ ix
បញ្ជីតារាង ........ xi
បញ្ជីអក្សរកាត់ ........ xii
ជំពូក ១៖ សេចក្តីផ្តើម ........ ១
១.១ សាវតារនៃការស្រាវជ្រាវ ........ ១
១.២ ចំណោទបញ្ហា ........ ២
១.៣ គោលបំណងនៃការស្រាវជ្រាវ ........ ៤
១.៤ គោលដៅនៃការស្រាវជ្រាវ ........ ៤
១.៥ សំណួរស្រាវជ្រាវ ........ ៤
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ ........ ៤
១.៧ និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ ........ ៦
១.៨ សេចក្តីសង្ខេបនៃជំពូក ........ ៦
ជំពូក ២៖ ការរំលឹកទ្រឹស្តី ........ ៧
២.១ និយមន័យនៃការអាន ........ ៧
២.២ កត្តាដែលនាំឱ្យខ្សោយការអាន ........ ៨
២.៣ ផលលំបាកនៃការអាន ........ ៨
២.៤ វិធីសាស្ត្រជួយដល់ផលលំបាកនៃការអាន ........ ៩
២.៥ គុណសម្បត្តិនៃការអាន ........ ១១
២.៦ សេចក្តីសង្ខេបនៃអត្ថបទ ........ ១១
ជំពូក ៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ ........ ១២
៣.១ គម្រោងការស្រាវជ្រាវ ........ ១២
៣.២ ទំហំសំណាក និងការធ្វើសំណាក ........ ១២
៣.៣ ឧបករណ៍សម្រាប់ការស្រាវជ្រាវ ........ ១៣
៣.៤ នីតិវិធីនៃការប្រមូលទិន្នន័យ ........ ១៣
៣.៥ ការវិភាគទិន្នន័យ ........ ១៤
៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ ១៤

៣.៧ សេចក្ដីសង្ខេបនៃជំពូក ........ ១៥
ជំពូក ៤៖ លទ្ធផលនៃការស្រាវជ្រាវ ........ ១៦
៤.១. ព័ត៌មានរបស់អ្នកចូលរួម ........ ១៦
៤.២. កត្តាដែលបណ្ដាលឱ្យសិស្សខ្សោយការអាន ........ ១៧
ក. ការយល់ឃើញរបស់គ្រូ ........ ១៧
១. កត្តាសុខភាព ........ ១៧
២. កត្តាគ្រួសារ (ឪពុកម្ដាយ ឬ អាណាព្យាបាល) ........ ១៧
៣. កត្តាបរិយាកាស ........ ១៨
ខ. ការយល់ឃើញរបស់សិស្ស ........ ១៩
៤.៣. បញ្ហាដែលសិស្សជួបប្រទះពេលខ្សោយការអាន ........ ២០
៤.៣.១ ការលើកឡើងរបស់គ្រូបង្រៀន ........ ២០
៤.៣.២ ការលើកឡើងរបស់សិស្ស ........ ២១
៤.៤ សេចក្ដីសង្ខេបនៃជំពូក ........ ២២
ជំពូកទី៥៖ ការពិភាក្សា ........ ២៣
៥.១ កត្តាបណ្ដាលឱ្យសិស្សខ្សោយការអាន ........ ២៣
៥.២ ផលប៉ះពាល់ទៅលើកម្សោយនៃការអាន ........ ២៤
៥.៣ សេចក្ដីសង្ខេបនៃជំពូក ........ ២៤
ជំពូកទី៦៖ សន្និដ្ឋាន ដែនកំណត់ និងសំណូមពរ ........ ២៥
៦.១ សេចក្ដីសន្និដ្ឋាន ........ ២៥
៦.២ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ........ ២៦
៦.៣ សំណូមពរ ........ ២៧
៦.៣.១ ចំពោះគ្រូបង្រៀន ........ ២៧
៦.៣.២ អាណាព្យាបាល ........ ២៧
៦.៣.៣ ចំពោះសាលា ឬគណៈគ្រប់គ្រង ........ ២៨
៦.៣.៤ ការសិក្សាស្រាវជ្រាវបន្ត ........ ២៨
៦.៤ សេចក្ដីសង្ខេបនៃជំពូក ........ ២៨
ឯកសារយោង ........ ៣០

# បញ្ជីតារាង

តារាង១...........................................................................................................................១២

ចំនួនគ្រូបង្រៀន និងសិស្ស ដែលត្រូវនឹងជ្រើសរើសធ្វើជាសំណាកក្នុងការសិក្សា

តារាង២...........................................................................................................................១៦

ព័ត៌មានរបស់អ្នកចូលរួមមានតួនាទីជាគ្រូបង្រៀននិងសិស្ស

# បញ្ជីអក្សរកាត់

| | | |
|---|---|---|
| PISA-D | Program for International Student Assessment for Development | កម្មវិធីវាយតម្លៃសិស្សជាអន្តរជាតិ |
| OECD | Organization for Economic Co-operation and Development | អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍ |

# ជំពូក ១៖ សេចក្តីផ្តើម

## ១.១ សារសំខាន់នៃការស្រាវជ្រាវ

ភាសានិងអក្សរសាស្ត្រខ្មែរ ជាអត្តសញ្ញាណនៃវប្បធម៌ និងប្រពៃណីរបស់ជាតិខ្មែរ។ ការចេះនិយាយ សរសេរ និងអានភាសាខ្មែរច្បាស់លាស់ហើយជ្រៅជ្រះ គឺជាការចាំបាច់សម្រាប់ពលរដ្ឋខ្មែរម្នាក់ៗ (ក្រសួងអប់រំ យុវជន និងកីឡា, ២០២០) ។ ក្នុងនោះដែរគេកត់សម្គាល់ឃើញថាសង្គមមួយដែលមានការរីកចម្រើន គឺសំបូរទៅដោយប្រជាជនអានច្រើន និងនិយមចូលចិត្តការសិក្សារៀនសូត្រជាប្រចាំ (ឡាំ, ២០១៩)។ ម្យ៉ាងវិញទៀត យោងតាមការស្រាវជ្រាវជាច្រើនបានបង្ហាញថា ការអានគឺជាជំនាញដ៏សំខាន់មួយដល់សិស្សានុសិស្សដើម្បីអាចទទួលបានភាពជោគជ័យក្នុងការសិក្សារបស់ពួកគេ រួមមានដូចជាសិស្សទទួលបាននូវចំណេះដឹងថ្មីៗតាមរយៈការអាន និងជួយសិស្សក្នុងការបកស្រាយអត្ថន័យនៃពាក្យ និងឃ្លាក្នុងល្បះ (Rajab et al., 2012)។ យ៉ាងណាមិញ Rajab et al. (2012) បានលើកឡើងដែរថា សិស្សដែលមិនយល់ពីអ្វីដែលពួកគេបានអាន នឹងប្រឈមទៅនឹងការបកស្រាយខ្លឹមសារ និងអត្ថន័យមិនបានត្រឹមត្រូវដែលអាចមានផលប៉ះពាល់ដល់លទ្ធផលសិក្សារបស់ពួកគេផងដែរ។ យោងតាមការស្រាវជ្រាវមួយចំនួនបានលើកឡើងថា គន្លឹះនៃភាពជោគជ័យក្នុងការសិក្សារបស់មនុស្សម្នាក់ៗអាស្រ័យទៅនឹងការអានព្រោះតាមរយៈការអានសិស្សអាចទទួលបាននូវចំណេះដឹងមិនត្រឹមតែផ្នែកភាសាប៉ុណ្ណោះទេ ប៉ុន្តែក៏ទទួលបាននូវចំណេះដឹងនៃការបកស្រាយខ្លឹមសារផងដែរ (Rahmat et al., 2020)។

យោងតាមសៀវភៅស្តង់ដារអំណានថ្នាក់ទី១ដល់ទី៣ បានលើកឡើងពីបំណិនអានទាំង៥៖ ការស្គាល់សូរ ការស្គាល់តួអក្សរនិងសូរ ការចេះអានស្ទាត់ ការចេះវាក្យសព្ទ និងការអានដើម្បីយល់ន័យ ពោលវា គឺជាការកំណត់ បំណិនអំណានពាក់ព័ន្ធនឹងបំណិនសំណេរ (សរសេរតាមអាន សំណេរអក្សរផ្ចង់ តែងល្បះ តែងសេចក្តី) ដែលសិស្សត្រូវទទួលបានតាមរយៈការហ្វឹកហាត់អាននិងសរសេរ សូរស្រះ ព្យញ្ជនៈ ពាក្យ ឃ្លា ល្បះ បានជោគជ័យ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦)។ លើសពីនេះទៅទៀត បុគ្គលម្នាក់ៗមានជំនាញនៃការអានផ្សេងៗគ្នា តាមរយៈការអប់រំ និងពេលវេលារបស់អ្នកអាន(Akyol et al., 2019)។ សព្វថ្ងៃនេះ ការអានត្រូវបានកំណត់ថាជាដំណើរការនៃការកសាងអត្ថន័យ ដែលចាំបាច់ណាស់

ក្នុងការប្រើប្រាស់ចំណេះដឹងពីមុនៗ ដោយផ្អែកលើការអនុវត្តឱ្យស្របតាមវិធីសាស្ត្រ និងគោលដៅប្រកបដោយប្រសិទ្ធភាព (Akyol, 2003) ។ ការអានដែលមានប្រសិទ្ធភាពរួមបញ្ចូលនូវគោលការណ៍មួយចំនួនដូចជា ភាពស្ទាត់ជំនាញ យុទ្ធសាស្ត្រ ការលើកទឹកចិត្ត ការអភិវឌ្ឍ និងការកសាងអត្ថន័យ (Anderson, et al., 1985) ។ មួយវិញទៀត ផលលំបាកក្នុងការអានត្រូវបានកំណត់ដោយជោគជ័យក្នុងការអានថានៅមានកម្រិតទាបជាងការរំពឹងទុកបើប្រៀបធៀបទៅនឹងអាយុ និងសក្ដានុពលនៃការសិក្សារបស់បុគ្គល និងការផ្លាស់ប្ដូររបស់សិស្សជាមួយនឹងបទពិសោធន៍វប្បធម៌ ភាសា និងការអប់រំ (Akyol និង Boyaci-Altinay, 2019)។

## ១.២ ចំណោទបញ្ហា

ភាសាខ្មែរ គឺជាភាសាមួយក្នុងចំណោមភាសាដែលស្មុគស្មាញជាងគេបំផុតជាច្រើននៅលើពិភពលោក ជាហេតុបង្កឱ្យមានការលំបាកដល់ការបង្រៀននិងរៀន។ ការគាំទ្រពីធនាគារពិភពលោកបានជំរុញឱ្យកម្ពុជាធ្វើការវាយតម្លៃថ្នាក់ជាតិលើកទីមួយរបស់ខ្លួនអំពីភាសាខ្មែរសម្រាប់សិស្សនៅក្នុងឆ្នាំ២០០៦ និងលើកទីពីរនៅឆ្នាំ២០០៩ ហើយការវាយតម្លៃនេះបានបង្ហាញថា សមត្ថភាពនៃការអានភាសាខ្មែររបស់សិស្សនៅមានកម្រិត (World Bank Group, 2016)។ មួយវិញទៀត បើយោងតាមប្រសាសន៍របស់ ឯកឧត្ដមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានថ្លែងនៅក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធី «កុមាររៀន កុមារចេះ» ជាផ្លូវការ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ថា កុមាររៀននៅថ្នាក់ទី៣ ប្រមាណជា៥០ភាគរយនៃចំនួនជិត៤សែននាក់ មិនចេះអានអក្សរបានត្រឹមត្រូវទេ។ ចំណែកសិស្សានុសិស្សនៅកម្រិតអនុវិទ្យាល័យថ្នាក់ទី៧ ចំនួន៣០ ទៅ៤០ភាគរយ ក្នុងចំណោមសិស្សជាង១សែននាក់មិនចេះអាន និងមិនចេះសរសេរភាសាខ្មែរច្បាស់លាស់ ជាហេតុធ្វើឱ្យការរៀនរបស់ពួកគេមិនមានប្រសិទ្ធភាពនិងប្រឈមនឹងការបោះបង់ការសិក្សាខ្ពស់ (កាន់, ២០២០)។

នៅកម្ពុជា តាមរយៈការធ្វើតេស្ត(PISA-D) ការអានរបស់សិស្ស បានបង្ហាញលទ្ធផលថា កម្រិតនៃការអានមានអត្រាទាបជាងមធ្យមភាគដែលបានកំណត់របស់ (PISA-D) ដែលការអានហាក់ដូចជាខ្សោយបំផុតក្នុងចំណោមមុខវិជ្ជាទាំងបី(គណិតវិទ្យា វិទ្យាសាស្ត្រ និងការអាន)។ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចនិងអភិវឌ្ឍ Organization for Economic Co-operation and Development (OECD ) និងបណ្ដា

ប្រទេសអាស៊ាន បង្ហាញថាការអនុវត្តនៅលើមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រត្រូវបានផ្សារភ្ជាប់ជាមួយនឹងប្រសិទ្ធភាពក្នុងការអាន ដែលបានឆ្លុះបញ្ចាំងឱ្យឃើញថា ការកែលម្អអក្ខរកម្មការអានរបស់សិស្ស គឺជាគន្លឹះនៃការអនុវត្តរបស់សិស្សក្នុងមុខវិជ្ជាផ្សេងៗទៀត។ ការអាន គឺជាជំនាញកម្រិតមូលដ្ឋាន ដែលត្រូវបានកំណត់ថា សិស្សមិនត្រឹមតែអាចអានអត្ថបទសាមញ្ញ ដែលធ្លាប់ស្គាល់ និងយល់អំពីព្យញ្ជនៈប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានសមត្ថភាពក្នុងការភ្ជាប់ព័ត៌មានមួយចំនួនបានផងដែរ(MoEYS, 2018)។ ការសិក្សាកន្លងមកបានលើកឡើងពី មូលហេតុមួយចំនួនដែលធ្វើឱ្យអ្នកអានពិបាកក្នុងការអាន ក្នុងនោះការសិក្សាបានរកឃើញថាអ្នកសិក្សាមួយចំនួនមានផលលំបាកក្នុងការយល់ពីខ្លឹមសារនៃអត្ថបទ គ្មានជំនួយក្នុងការអាន ខ្ជិលក្នុងការអាន និងមិនមានការផ្ដោតអារម្មណ៍ទៅលើការអាន (Garcia et al., 2014)។ បន្ថែមពីនេះទៀត ផលលំបាកក្នុងការអានត្រូវបានជួបប្រទះនូវបញ្ហាមួយចំនួនទាក់ទងទៅនឹងវាក្យសព្ទ ដែលសិស្សមិនយល់ពីអត្ថន័យនៃពាក្យដែលបានអាន ហើយអ្នកអានមានការព្រួយបារម្ភខ្លាំងបំផុតនៅពេលដែលពួកគេជួបប្រទះ ល្បះដែលវែង និងស្មុគស្មាញ ឬល្បះដែលពួកគេមិនច្បាស់ពីវេយ្យាករណ៍ និងជាពិសេសវិធីសាស្ត្របង្រៀន ដែលសិស្សមានការព្រួយបារម្ភខ្លាំងបំផុតនៅពេលនៅពេលដែលគ្រូបានជ្រើសរើសអត្ថបទដែលពួកគេមិនចាប់អារម្មណ៍ (Rahmat et al., 2020c)។

នៅថ្នាក់អនុវិទ្យាល័យកម្រិតសិស្សថ្នាក់ទី៧មួយចំនួននៅខាងអនុវិទ្យាល័យស្រុក ខេត្តកំពង់ចាមខ្សោយក្នុងការអានភាសាខ្មែរ និងអានដោយភាពរដាក់រដុប។ ទាំងនេះគឺជាផ្នែកនៃការលំបាករបស់សិស្សក្នុងការសិក្សាដើម្បីចាប់យកចំណេះដឹងដែលជាហេតុធ្វើឱ្យអត្រាសិស្សបោះបង់ចោលការសិក្សាច្រើន។ ចំពោះបញ្ហាទាំងអស់នេះមិនត្រឹមតែកើតមានឡើងចំពោះបរិបទប្រទេសកម្ពុជាតែប៉ុណ្ណោះទេ ប៉ុន្តែជាបញ្ហាដែលកើតមានឡើងស្ទើគ្រប់ប្រទេសទាំងអស់ទូទាំងពិភពលោក ដែលជាហេតុផលមួយជំរុញឱ្យអ្នកស្រាវជ្រាវធ្វើការសិក្សាទៅលើកម្សោយនៃការអានរបស់សិស្សក្នុងករណីសិក្សាមួយកន្លែង។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីកំណត់ឱ្យបានពីមូលហេតុនៃភាពកម្សោយក្នុងការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧។ បន្ថែមពីលើនេះ ការស្រាវជ្រាវនេះនឹងស្វែងយល់អំពីបញ្ហាដែលសិស្សជួបប្រទះនូវមូលហេតុដែលខ្លួនខ្សោយអំណាន។

## ១.៤ គោលដៅនៃការស្រាវជ្រាវ

តាមរយៈការស្រាវជ្រាវមួយនេះ មានគោលដៅសិក្សាពីរសំខាន់ៗដូចខាងក្រោម :

១. កំណត់ឱ្យបានពីមូលហេតុរបស់សិស្សថ្នាក់ទី៧ដែលខ្សោយក្នុងការអាន។

២. កំណត់ឱ្យបានពីបញ្ហាដែលសិស្សបានជួបប្រទះនៅពេលខ្សោយក្នុងការអានភាសាខ្មែរ។

## ១.៥ សំណួរស្រាវជ្រាវ

តាមរយៈគោលបំណងនៃការស្រាវជ្រាវគឺដើម្បីស្វែងយល់ពីមូលហេតុ និងផលវិបាកការដែលសិស្សជួបប្រទះនូវក្នុងអានភាសាខ្មែរ។

ដូច្នេះ ដើម្បីសម្រេចបាននូវវត្ថុបំណងនៃការស្រាវជ្រាវនេះ សំណួរចំនួនពីរត្រូវបានកំណត់ដូចខាងក្រោម :

១- តើកត្តាអ្វីខ្លះដែលបណ្តាលឱ្យសិស្សថ្នាក់ទី៧នៅអនុវិទ្យាល័យស្រែកខ្សោយក្នុងការអានភាសាខ្មែរ?

២- តើសិស្សបានជួបប្រទះបញ្ហាអ្វីខ្លះនៅពេលពួកគេខ្សោយក្នុងការអានភាសាខ្មែរ?

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះបានផ្តោតសំខាន់ទៅលើផលលំបាកក្នុងការអានភា សាខ្មែរ ហើយលទ្ធផលនៃការស្រាវជ្រាវនេះរំពឹងថានឹងផ្តល់សារៈសំខាន់ រួមទាំងប្រយោជន៍ដល់អ្នកដែលពាក់ព័ន្ធដូចតទៅ៖

ទីមួយគឺ ចំពោះអ្នកស្រាវជ្រាវផ្ទាល់ដែលមានតួនាទីជាគ្រូបង្រៀននិងគ្រូបង្រៀនទាំងអស់ ។ ការសិក្សាមួយនេះនឹងដើរតួជាផែនទីក្នុងការបង្ហាញផ្លូវក្នុងការបង្រៀនសិស្សដែលខ្សោយក្នុងការអានឱ្យបានត្រឹមត្រូវលើមុខវិជ្ជាភាសាខ្មែរ។ ម្យ៉ាងវិញទៀត ការសិក្សានេះនឹងផ្តល់អោយគ្រូបង្រៀនយល់ដឹងបានស៊ីជម្រៅទៅលើបញ្ហាប្រឈមនានាដែលនឹងកើតមានចំពោះសិស្ស និងដំណោះស្រាយមួយចំនួន ដើម្បីជាគន្លឹះសម្រាប់គ្រូបង្រៀនបានត្រៀមនូវលក្ខណៈដោះស្រាយនិងពង្រីកចំពោះបញ្ហាទាំងនោះ ។ លើសពីនេះ

ទៅទៀត ការសិក្សានេះនឹងរួមចំណែកក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់គ្រូបង្រៀនភាសាខ្មែរឱ្យមានទំនុកចិត្ត វិធីសាស្ត្រផ្សេងៗដើម្បីបង្រៀនសិស្សដែលខ្សោយក្នុងការអាន និងប្រើប្រាស់ទៅដោយមានប្រសិទ្ធភាព។ ការដែលគ្រូបានស្វែងយល់ច្បាស់អំពីវិធីសាស្ត្រ និងដំណោះស្រាយដែលអាចជួយសិស្សខ្សោយក្នុងការអានហើយនោះនឹងអាចជួយសិស្សបានទាន់ពេលវេលាផងដែរ។ ជាពិសេសការសិក្សានេះនឹងបើកបង្ហាញនូវមូលហេតុ និងបញ្ហាមួយចំនួនជូនដល់គ្រូបង្រៀនដែលមានបំណងជួយពង្រឹងបន្ថែមដល់សិស្សដែលខ្សោយក្នុងការអានភាសាខ្មែរ និងជាជំនួយដល់ការបង្រៀនរបស់ខ្លួនឱ្យកាន់តែមានប្រសិទ្ធភាព។ ជាចុងក្រោយ ការសិក្សាមួយនេះចង់ជំរុញនិងលើកទឹកចិត្តគ្រូបង្រៀនភាសាខ្មែរឱ្យស្វែងយល់ និងពង្រឹងការយកចិត្តទុកដាក់ចំពោះសិស្សបន្ថែមទៀតដើម្បីជាជំនួយទៅកាន់សិស្សក្នុងការសិក្សា។

ទីពីរគឺ ចំពោះសិស្ស ។ សិស្សនឹងទទួលបាននូវបំណិនក្នុងការអាន និងរួមចំណែកក្នុងការអភិវឌ្ឍការសិក្សារបស់សិស្សឱ្យកាន់តែប្រសើរឡើង។ មួយវិញទៀតសិស្សនឹងមានទំនុកចិត្ត និងអារម្មណ៍សុវត្ថិភាពក្នុងការសិក្សាដោយមានការយកចិត្តទុកដាក់ពីសំណាក់គ្រូបង្រៀនផ្ទាល់។

ទីបីគឺ ចំពោះគណៈគ្រប់គ្រងសាលា ។ តាមរយៈលទ្ធផលនៃការសិក្សានេះ អ្នកស្រាវជ្រាវរំពឹងថានឹងជាប្រយោជន៍សម្រាប់គណៈគ្រប់គ្រងសាលាក្នុងការជួយសម្រួលទៅលើផ្នែកផ្សេងៗដែលជាបញ្ហាប្រឈមរាំងស្ទះដែលបណ្តាលឱ្យសិស្សខ្សោយក្នុងការអាន។ម្យ៉ាងវិញទៀត ការសិក្សានេះក៏អាចជាគំនិតមួយសម្រាប់គណៈគ្រប់គ្រងសាលារៀនពិចារណាក្នុងការណែនាំដល់គ្រូបង្រៀនអោយយកចិត្តទុកដាក់ និងចូលរួមអនុវត្តន៍វិធីសាស្ត្របង្រៀនមួយចំនួនដែលអាចជួយសិស្សឱ្យកាន់តែច្រើន។

ជាចុងក្រោយ អ្នកស្រាវជ្រាវរំពឹងថាការសិក្សាមួយនេះនឹងដាស់អារម្មណ៍គ្រូបង្រៀនមុខវិជ្ជាភាសាខ្មែររួមទាំងគ្រូបង្រៀនគ្រប់មុខវិជ្ជាទាំងអស់អោយជួយផ្តោត និងយកចិត្តទុកដាក់ចំពោះផលវិបាករបស់សិស្សក្នុងការអានឱ្យបានច្រើនដើម្បីជួយបង្កើននូវធនធានមនុស្សឱ្យកាន់តែមានប្រសិទ្ធភាពនិងមានសមត្ថភាព។

## ១.៧ និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ

**ការអាន** គឺជាសកម្មភាពមួយដើម្បីទទួលបានអត្ថន័យពីអ្វីដែលបានអាន និងជាវិធីមួយក្នុងការប្រើប្រាស់នូវសមត្ថភាពដើម្បីយល់ និងបកស្រាយអត្ថន័យ។

**កម្សោយការអាន** គឺជាការលំបាកក្នុងការអាន ការប្រកប ស្រះ ព្យញ្ជនៈ ឱ្យចេញជាពាក្យ។

## ១.៨ សេចក្តីសង្ខេបនៃជំពូក

នៅក្នុងជំពូកនេះ បានលើកឡើងទាក់ទងនឹងទិដ្ឋភាពទូទៅនៃសាវតានៃការស្រាវជ្រាវដែលទាក់ទងនឹងការអាននិងបំណិនទាំងប្រាំ ក៏ដូចជាបើកបង្ហាញពីបញ្ហាដែលជួបប្រទះ និងការស្រាវជ្រាវមួយចំនួនបានរកឃើញផងដែរ។ លើសពីនេះទៀត ការស្រាវជ្រាវនេះ មានគោលបំណងនិងគោលដៅចង់ស្វែងរកពីមូលហេតុរបស់សិស្សថ្នាក់ទី៧ដែលខ្សោយក្នុងការអាន និងកំណត់ឱ្យបានពីបញ្ហាដែលសិស្សបានជួបប្រទះនៅពេលខ្សោយក្នុងការអានភាសាខ្មែរ។ ចំពោះការស្រាវជ្រាវនេះ មានសារៈសំខាន់ដល់សិស្ស លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រងជាពិសេសផងដែរ។

# ជំពូក ២៖ ការរំលឹកទ្រឹស្ដី

ក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងបង្ហាញអំពីនិយមន័យនៃការអាន ផលលំបាកនៃការអាន កត្តាដែលនាំឱ្យខ្សោយការអាន ផលប៉ះពាល់ទៅលើកម្សោយការអាន វិធីសាស្ត្រជួយដល់ផលលំបាកនៃការអានគុណសម្បត្តិនៃការអាន។

## ២.១ និយមន័យនៃការអាន

ការអានគឺជាប្រភេទជាតុផ្សំនៃដំណើរការបង្រៀន និងរៀន ដែលនាំឱ្យការអានក្លាយជាជំនាញមូលដ្ឋានដ៏សំខាន់បំផុតមួយដែលរួមចំណែកដល់ការទទួលបានព័ត៌មាន និងការរៀនដោយស្វ័យភាពរបស់សិស្ស (Leppanen et al., 2008)។ ការអានអាចជាសមត្ថភាពស្មុគស្មាញ ហើយមានជាតុផ្សំផ្សេងៗគ្នាដែលអាចពាក់ព័ន្ធនឹងបញ្ហាសរីរវិទ្យា និងបញ្ហាផ្លូវចិត្តដែលមានឥទ្ធិពលលើវិធីសាស្ត្រនៃការអាន។លើសពីនេះទៅទៀត ជាតុសំខាន់ៗក្នុងការអានមានចំនួនប្រាំ៖ ការយល់ដឹងសូរសព្ទ សូរសព្ទ ការណែនាំវាក្យសព្ទយុទ្ធសាស្ត្រយល់អត្ថបទ និងការអានស្ទាត់ (Therrien, 2004)។ បន្ថែមពីនេះទៀត បើយោងទៅតាមឯកសារតេស្តស្តង់ដារថ្នាក់ទី១ដល់ទី៣ បានលើកឡើងពីបំណិនអានទាំង៥គឺ៖ (១) ការស្គាល់សូរ គឺសំដៅការបង្រៀនដើម្បីជួយឱ្យ សិស្សមានសមត្ថភាពកំណត់ប្រើប្រាស់និងញែកសូរក្នុង ពាក្យ។ ឧទាហរណ៍ សិស្សប្រាប់សូរតួអក្សរក្នុងពាក្យ ថា៉ (ថនិងអា "o")តាមរយៈរូបភាព ឬការស្តាប់ពីគ្រូ។ (២) ការស្គាល់តួអក្សរនិងសូរ គឺសំដៅដល់ការបង្រៀន ដែលជួយដល់អ្នកអាន (សិស្ស) យល់និងអនុវត្តចំណេះ ដឹងស្តីពីទំនាក់ទំនងរវាងតួអក្សរនិងសូរ។ ឧទាហរណ៍ សិស្សអាចប្រាប់គ្រូថារូបភាពនៃពាក្យ ថា មានសូរតួអក្សរ ថ។ (៣) ការចេះអានស្ទាត់ គឺសំដៅការបង្រៀនដែលជួយ ពង្រឹងដល់សមត្ថភាពអានឮដោយមានល្បឿនច្បាស់លាស់និងការបង្ហាញគំនិតត្រឹមត្រូវ។ ឧទាហរណ៍ សិស្សអាចអានពាក្យ ឃ្លា ឬល្បះឮខ្លាំងៗ ហើយលឿន។ (៤) ការចេះវាក្យសព្ទ គឺសំដៅការបង្រៀនដើម្បីបង្កឱ្យ មានចំណេះដឹងស្តីពីពាក្យ។ រាប់ទាំងពាក្យប្រើប្រាស់ ផ្ទាល់ខ្លួន និងពាក្យសរសេរ ដូចជាតាមរយៈការស្តាល់ ពាក្យដោយការឮនិងឃើញ មើល ឬអាន។ ឧទាហរណ៍ សិស្សអាចអានពាក្យចំណាំប្រើញឹកញាប់ ដែលគ្រូសរសេរលើក្តារខៀន ឬបង្ហាញលើបណ្ណពាក្យ។(៥) ការអានដើម្បីយល់ន័យ គឺសំដៅការបង្រៀនដែលធ្វើ ឱ្យសិស្សមានសមត្ថភាពចូលរួមនិង

បញ្ចេញន័យដោយ ប្រើពាក្យសម្ដីផ្ទាល់ខ្លួនពីអត្ថបទដែលបានអាន។ឧទាហរណ៍ សិស្សអាចប្រាប់គ្រូអំពីអត្ថន័យនៃល្បះ ដោយប្រើពាក្យសម្ដីផ្ទាល់ខ្លួន (ក្រសួង អប់រំ យុវជន និងកីឡា, ២០១៦) ។

## ២.២ កត្តាដែលនាំឱ្យខ្សោយការអាន

ជាទូទៅ សិស្សដែលមានផលពិបាកក្នុងការអានគឺមកពីគ្រួសារដែលមានសមាជិកច្រើននិងស្ថិតក្នុងភាពក្រីក្រ ដែលមានកម្រិតអប់រំទាប និងឱកាសទំនាក់ទំនងនៅមានកម្រិតជាមួយនឹងការអប់រំ។ សិស្សដែលពិបាកអានមានបញ្ហាមើលនិងស្ដាប់ ដោយមានការបញ្ជាក់ពីគ្រូ និងការលើកទឹកចិត្តមានកម្រិតទាប។ សិស្សអានយឺត ហើយមានកំហុសច្រើន ក៏ដោយសារមិត្តរួមថ្នាក់ចំអកជាមួយរឿងទាំងនេះនៅក្នុងថ្នាក់រៀន។ ស្ថានភាពនេះធ្វើឱ្យសិស្សក្លាយជាមនុស្សឆេវឆាវ ដែលរារាំងមិនឱ្យពួកគេមានទំនាក់ទំនងល្អនិងគ្នា។ កម្មវិធីបណ្ដុះបណ្ដាលនឹងមានប្រសិទ្ធភាពដើម្បីបង្កើនការអាន និងភាពជោគជ័យក្នុងការសិក្សា។ ការស្ទាក់ស្ទើរក្នុងការអាន និងមានអារម្មណ៍មិនស្រួលក្នុងអំឡុងពេលធ្វើសកម្មភាពអានដែលបានអនុវត្តនៅក្នុងថ្នាក់ ដោយហេតុផលដូចជាការអានមិនត្រឹមត្រូវ ឬការរំខានជាបន្តបន្ទាប់ដោយមិត្តរួមថ្នាក់របស់ពួកគេ។ ឪពុកម្ដាយ គ្រូបង្រៀនក្នុងថ្នាក់ កង្វះការលើកទឹកចិត្តក្នុងការអានដែលធ្វើឱ្យភាពជោគជ័យក្នុងការសិក្សានៅមានកម្រិតទាបនៅស្ទើរគ្រប់ថ្នាក់ មិនបានអាននៅផ្ទះ។ ជាមួយនឹងគោលបំណងនៃការដោះស្រាយបញ្ហានេះ សំខាន់បំផុត ត្រូវបំបាត់ការរំខានផ្សេងៗ និងផ្ដល់នូវបរិយាកាសស្ងប់ស្ងាត់ ដើម្បីដឹកនាំចំណាប់អារម្មណ៍របស់សិស្សចំពោះការអាន ហេតុដូចនេះ ការលើកទឹកចិត្តកុមារឱ្យអាន គឺជាកត្តាសំខាន់មួយក្នុងការរៀនអាន និងអភិវឌ្ឍការអាន ដែលសិស្សត្រូវបានផ្ដល់ព័ត៌មានជាបន្តបន្ទាប់អំពីគោលបំណងនៃការអាន (Akyol, 2013) ។

## ២.៣ ផលលំបាកនៃការអាន

កត្តាជាច្រើនអាចជះឥទ្ធិពលទៅដល់សមិទ្ធិផលនៃការយល់ដឹងក្នុងការអានរបស់សិស្ស ដែលលទ្ធផលស្រាវជ្រាវបានបង្ហាញថា ដោយសារតែបរិយាកាសសិក្សាមិនល្អ កង្វះការលើកទឹកចិត្តក្នុងការអាន និងយុទ្ធសាស្ត្រអានដ៏មានប្រសិទ្ធភាព (Eurydice, 2011)។ មួយវិញទៀត Chiu និង McBride-Chang (2006, 2010) បានរកឃើញថា ស្ថានភាពសេដ្ឋកិច្ចសង្គមគ្រួសាររបស់សិស្សមានទំនាក់ទំនងជាវិជ្ជមានទៅ

នឹងសមិទ្ធផលនៃការអានរបស់ពួកគេ។ លើសពីនេះទៅទៀត សិស្សមកពីគ្រួសារដែលមានវិបត្តិសេដ្ឋកិច្ចសង្គម មានទំនោរក្នុងការចុះឈ្មោះកូនឱ្យចូលរៀននៅសាលាដែលមានធនធានមិនល្អ ដូចជាគុណភាពគ្រូទាប និងកន្លែងបង្រៀន និងរៀនអន់ (OECD, 2011, 2016a)។ ដោយឡែក សិស្សដែលមានផលលំបាកក្នុងការអាន ត្រូវបានទទួលរងការគំរាមកំហែងពីមិត្តភក្តិ និងមានអារម្មណ៍ថាអ្នកដទៃមើលងាយ។ បន្ថែមពីនេះទៀត សិស្សដែលមានការលំបាកក្នុងការអានគឺមានភាពស្ងប់ស្ងាត់ អៀនច្រើន និងជៀសវាងអ្វីៗទាំងអស់ដែលទាក់ទងនឹងការអានតាមដែលអាចធ្វើទៅបាន (Kayabasi, 2017)។

## ២.៤ វិធីសាស្ត្រជួយដល់ផលលំបាកនៃការអាន

គំនិតនេះគឺជាការប្រសើរក្នុងការកំណត់អត្តសញ្ញាណកុមារដែលមានបញ្ហាអានឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងផ្តល់ការណែនាំចាំបាច់ជាជាងកំណត់អត្តសញ្ញាណ និងមានទំហំធំ ចំនួនសិស្សដែលមានបញ្ហារបស់ពួកគេនៅតែបន្តដោយគ្មានជំនួយក្នុងការបង្រៀនដែលត្រូវការ។ វិធីដែលជួយបញ្ហាក្នុងការអានត្រូវបានបង្ហាញនៅក្នុង "Tiers of សេចក្តីណែនាំ" ខាងក្រោម។ នៅក្នុងប្រព័ន្ធគាំទ្រ សិស្សទាំងអស់ត្រូវបានពិនិត្យ។ អ្នកដែលប្រឈមមុខនឹងការលំបាកក្នុងការអាន ទទួលបានការបង្រៀនអក្ខរកម្មកម្រិតទី ១ ដោយផ្អែកលើភស្តុតាងជាបន្តបន្ទាប់នៅក្នុងថ្នាក់រៀន។ ការត្រួតពិនិត្យវឌ្ឍនភាព ហើយប្រសិនបើចាំបាច់ អន្តរាគមន៍កម្រិត ២ នោះ។ ដោះស្រាយបញ្ហាអក្ខរកម្មជាក់លាក់របស់ពួកគេ។ អន្តរាគមន៍កម្រិត ២ នេះអាចត្រូវបានផ្តល់ជូនដោយគ្រូថ្នាក់រៀន ដែលជាអ្នកបណ្តុះបណ្តាលជំនួយការបង្រៀនដែលគ្រប់គ្រងដោយគ្រូក្នុងថ្នាក់ អ្នកជំនាញផ្នែកអប់រំ ដូចជាគ្រូ។ អន្តរកម្មកម្រិត ២ មិនមែនជាផ្នែកនៃការអប់រំពិសេសទេ ប៉ុន្តែជាផ្នែកបន្ថែម ឬបន្ថែមនៅក្នុងការអប់រំទូទៅ។ សិស្សចូលរួមក្នុងអន្តរាគមន៍កម្រិត ២ សម្រាប់រយៈពេលជាក់លាក់មួយ ជាធម្មតា ៨-១២ សប្តាហ៍ ជាមួយនឹងការត្រួតពិនិត្យវឌ្ឍនភាពជាបន្តបន្ទាប់ ប្រហែលរៀងរាល់ពីរសប្តាហ៍ម្តង។ ដោយប្រើទិន្នន័យតាមដានវឌ្ឍនភាព និងការសង្កេតរបស់គ្រូ ការឆ្លើយតបរបស់សិស្សម្នាក់ៗចំពោះការណែនាំអក្ខរកម្មត្រូវបានកំណត់ (ឧ. តើសិស្សឈានដល់កម្រិតដែលរំពឹងទុកទេ?)។ ប្រសិនបើការឆ្លើយតបរបស់សិស្សមិនគ្រប់គ្រាន់ដើម្បីបំពេញតាមគោលការណ៍ត្រួតពិនិត្យវឌ្ឍនភាព មានជម្រើសជាច្រើន រួមទាំងការកែតម្រូវការណែនាំ ការផ្លាស់ប្តូរក្រុម កែតម្រូវទំហំក្រុម ការផ្លាស់ប្តូរកា

អន្តរាគមន៍ (ដែលអាចយូរជាងនេះ ឧ. ៣០-៤៥ នាទី ជាជាង ២០ នាទី និងច្រើនទៀតតាមតម្រូវការរបស់សិស្សម្នាក់ៗ)។ ប្រសិនបើការឆ្លើយតបការបង្រៀនមិនគ្រប់គ្រាន់នៅតែបន្ត ក្រុមអប់រំ ឬមាតាបិតា/អាណាព្យាបាលអាចកំណត់ថាការវាយតម្លៃសិទ្ធិទទួលបានការអប់រំពិសេសគឺស្ថិតនៅក្នុងលំដាប់។ អត្ថប្រយោជន៍នៃវិធីសាស្រ្តនេះគឺថាសិស្សត្រូវបានផ្តល់ឱ្យសមរម្យ ការណែនាំផ្អែកលើភស្តុតាងដំបូង សម្រាប់សិស្សភាគច្រើន អន្តរាគមន៍លំដាប់ទី២ យ៉ាងឆាប់រហ័សនេះគឺគ្រប់គ្រាន់សម្រាប់ការក្លាយជាអ្នកអានខ្លាំង។ មានតែសិស្សដែលមានការលំបាកក្នុងការអានជាប់លាប់ ដែលនឹងត្រូវបានបញ្ជូនទៅការអប់រំពិសេស។ ការអាន ( ឧ. គំរូអក្ខរាវិរុទ្ធសំឡេង វាក្យសព្ទ ) ត្រូវបានបង្រៀន។ ប្រភេទនៃការឆ្លើយតបដែលសិស្សផ្តល់អាចណែនាំដោយគូសបញ្ជាក់ពីតម្រូវការរបស់សិស្សម្នាក់ៗសម្រាប់ការបង្រៀនឡើងវិញ និងការអនុវត្តបន្ថែម ខណៈដែលជាតុទាំងនោះហាក់ដូចជាទទួលបានជោគជ័យ។ វិធានការដែលអាចជួយសម្រួលដល់កម្មវិធីសិក្សា ( ឧ ត្រូវការកម្មវិធីបន្ថែម ឬផ្សេងគ្នា ) ការដាក់សិស្សជាក្រុម ( ឧ. សិស្សមួយចំនួនអាចទទួលបានអត្ថប្រយោជន៍និងរៀនពីសមាជិកក្រុមបានល្អប្រសើរ។ ចំណែកអ្នកផ្សេងទៀតអាចទទួលបានអត្ថប្រយោជន៍ពីមេរៀនមួយតាមរយៈការធ្វើការជាបុគ្គល។ ជាពិសេសទិន្នន័យតាមដានវឌ្ឍនភាពដែលកំពុងដំណើរការអាចជូនដំណឹងដល់ការសម្រេចចិត្តអំពីការបញ្ជូនសិស្សទៅក្នុងការអប់រំពិសេស (Vaughn, 2021)។ Richek et al (2002) បានលើកឡើងថាដើម្បីអភិវឌ្ឍភាពស្ទាត់ជំនាញក្នុងការអាន សិស្សត្រូវអានសៀវភៅដែលងាយស្រួលនិងមានពាក្យដែលពួកគេស្គាល់។ ការអានគួរតែចាប់ផ្តើមជាមួយរយៈពេល ១០ នាទី ហើយបន្ទាប់មករយៈពេលនេះគួរតែកើនឡើងបន្តិចម្តងៗដល់ ២០-២៥នាទី ដោយសារសិស្សមិនអាចផ្តោតលើអត្ថបទដែលពួកគេអានជាយូរនោះទេ។ សម្រាប់ហេតុផលនេះ នៅពេលដែលអត្ថបទដែលត្រូវអានដោយសិស្សក្នុងការសិក្សាត្រូវបានជ្រើសរើស នោះត្រូវបានផ្តល់អាទិភាពដល់អត្ថបទដែលមានពាក្យប៉ុន្មានឃ្លា និងរួមបញ្ចូលទាំងសំឡេងដែលសិស្សយល់ច្រឡំ។ ក្រោយមកសកម្មភាពត្រូវបានអនុវត្តចេញជាមួយអត្ថបទដែលមានពាក្យកាន់តែច្រើនឡើងៗបន្តិចម្តងៗ។

## ២.៥ គុណសម្បត្តិនៃការអាន

យោងទៅតាម Specktor, (2018) ការអានអាចធ្វើអោយអ្នកអានក្លាយជាមនុស្សល្អជាងមុន ព្រោះវាជួយអ្នកអានឱ្យមានការយល់ចិត្ត និងបញ្ញាផ្លូវចិត្តបានកាន់តែច្រើន។ នេះគឺដោយសារតែវាជួយឱ្យអ្នកអានមើលឃើញពីពិភពលោកនូវទស្សនៈជាច្រើន ហើយថែមទាំងនាំអ្នកអានទៅរកអន្តរកម្មរបស់មនុស្សបានកាន់តែច្រើន ដែលអាចធ្វើឱ្យកម្រិតស្ត្រេសទាប។ ជាងនេះទៅទៀត Erasmus, (2018) លើកឡើងថាការអានក៏អាចជួយឱ្យមនុស្សជៀសផុតពីជំងឺធ្លាក់ទឹកចិត្ត ភាពតានតឹង និងអស់កម្លាំងដោយការប្រើប្រាស់បច្ចេកវិទ្យាជំនាន់ Z រៀងរាល់វិនាទីក្នុងមួយថ្ងៃ។ ដូច្នេះហើយ ការអានត្រូវបានបង្ហាញតាមបែបវិទ្យាសាស្ត្រថា អាចកាត់បន្ថយភាពតានតឹង និងផ្តល់អត្ថប្រយោជន៍ដល់សុខភាពបានផងដែរ។ ជាការពិត ការអានក៏ធ្វើឱ្យមនុស្សម្នាក់កាន់តែមានភាពឆ្លាតវៃបានយូរអង្វែង ដោយសារខួរក្បាលជាសាច់ដុំ ហើយនៅពេលមនុស្សអាន វានឹងជំរុញឱ្យខួរក្បាល ពង្រឹងមុខងារចងចាំ (Noor, et al., 2018)។

## ២.៦ សេចក្តីសង្ខេបនៃអត្ថបទ

នៅក្នុងជំពូកទី២នេះ បានលើកឡើងទាក់ទងនឹងនិយមន័យនៃការអានប្រភេទជាតុផ្សំនៃដំណើរការបង្រៀន និងរៀន ដែលនាំឱ្យការអានក្លាយជាជំនាញមូលដ្ឋានដ៏សំខាន់បំផុតមួយដែលរួមចំណែកដល់ការទទួលបានព័ត៌មាន និងការរៀនដោយស្វ័យភាពរបស់សិស្ស និងបានបើកបង្ហាញពីកត្តាដែលនាំឱ្យខ្សោយការអាន ផលលំបាកនៃការអាន វិធីសាស្ត្រជួយដល់ផលលំបាកនៃការអាន គុណសម្បត្តិនៃការអានដែលបានបង្ហាញតាមបែបវិទ្យាសាស្ត្រថា អាចកាត់បន្ថយភាពតានតឹង និងផ្តល់អត្ថប្រយោជន៍ដល់សុខភាពបានផងដែរ។

# ជំពូក ៣៖ វិធីសាស្ត្រនៃការស្រាវជ្រាវ

ជំពូកទី៣នេះ បង្ហាញអំពីដំណើរការនៃគម្រោងស្រាវជ្រាវដែលអ្នកស្រាវជ្រាវបានប្រើប្រាស់ក្នុងការជ្រើសរើសសំណាក ទំហំសំណាក នីតិវិធីក្នុងការប្រមូលទិន្នន័យ ដំណើរការនៃការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ ព្រមទាំងក្រមសីលធម៌ក្នុងការស្រាវជ្រាវ និងដែនកំណត់នៃការស្រាវជ្រាវផងដែរ ។

## ៣.១ គម្រោងការស្រាវជ្រាវ

អ្នកស្រាវជ្រាវប្រើប្រាស់វិធីស្រាវជ្រាវតាមបែបគុណវិស័យក្នុងការសិក្សានេះ ដោយផ្អែកតាមគោលបំណងនៃការស្រាវជ្រាវខាងលើ ។ មួយវិញទៀត ការប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យនេះ គឺដើម្បីស្វែងរកគំនិតស៊ីជម្រៅពីអ្នកចូលរួមក្នុងការពិចារណាជាច្រើនជាមួយស្ថានភាពដែលបានជួបប្រទះ និងបទពិសោធកន្លងមករបស់អ្នកចូលរួមដើម្បីឆ្លើយតបទៅនឹងគោលបំណងដែលអ្នកស្រាវជ្រាវចង់បាន។ ចំពោះការប្រើប្រាស់វិធីសាស្ត្រនេះ អ្នកស្រាវជ្រាវអាចមានលទ្ធភាពបត់បែនវិធីសាស្ត្រ ឬយុទ្ធសាស្ត្រនៃការស្រាវជ្រាវបានក្នុងកំឡុងពេលនៃដំណើរការស្រាវជ្រាវ និងប្រើប្រាស់សំណួរបើកនិងសំណួរបែបប្រជេញទៅកាន់អ្នកចូលរួម ដើម្បីរកឱ្យបាននូវទិន្នន័យស៊ីជម្រៅ។

## ៣.២ ទំហំសំណាក និងការធ្វើសំណាក

ទំហំសំណាកគឺជាដំណើរការនៃការជ្រើសរើសអ្នកដែលត្រូវចូលរួមក្នុងកិច្ចការស្រាវជ្រាវ ដើម្បីសម្រេចនូវគោលបំណងនៃការស្រាវជ្រាវនេះ អ្នកស្រាវជ្រាវកំណត់យកប្រភេទសំណាកគំរូមានគោលបំណង(Purposive Sampling) ដែលអ្នកស្រាវជ្រាវមានចេតនាជ្រើសរើសបុគ្គលនិងតំបន់ណាមួយដើម្បីសិក្សា ឬបានយល់ដឹងពីបញ្ហាដែលទាក់ទងប្រធានបទចង់ស្រាវជ្រាវ។ មួយវិញទៀត អ្នកស្រាវជ្រាវដឹងច្បាស់ថា អ្នកចូលរួមដែលបានជ្រើសរើសមានព័ត៌មានដែលអ្នកស្រាវជ្រាវចង់បាន ដោយអ្នកស្រាវជ្រាវនឹងប្រមូលទិន្នន័យពីគ្រូដែលបានបង្រៀនមុខវិជ្ជាភាសាខ្មែរ និងសិស្សដែលខ្សោយក្នុងការអានភាសាខ្មែរ។ ដូច្នេះហើយ អ្នកស្រាវជ្រាវបានជ្រើសរើសគ្រូថ្នាក់ទី ៧ ចំនួន ១នាក់ ពីអនុវិទ្យាល័យមួយកន្លែង ស្ថិតក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ដែលជាគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ។ មួយវិញទៀត អ្នកស្រាវជ្រាវបានជ្រើសរើសសិស្សខ្សោយក្នុងការអានភាសាខ្មែរនៅកម្រិតថ្នាក់ទី ៧ ចំនួន ៦នាក់ ក្នុងចំណោមសិស្សពីរថ្នាក់

ដោយចំនួនកម្រិតថ្នាក់ទី៧ សរុបមាន២ថ្នាក់ ក្នុងមួយថ្នាក់អ្នកស្រាវជ្រាវជ្រើសរើសយកចំនួន ៣នាក់ ពីព្រោះអ្នកស្រាវជ្រាវគិតពីពេលវេលា និងភាពងាយស្រួលក្នុងការប្រមូលទិន្នន័យ ហើយការកំណត់អត្តសញ្ញាណទៅលើសិស្សខ្សោយនៃការអានគឺធ្វើឡើងតាមរយៈការសាកសួរទៅកាន់គ្រូ ដែលបានបង្រៀនមុខវិជ្ជាភាសាខ្មែរផ្ទាល់ និងមើលលើ លទ្ធផលនៃការសិក្សាលើលទ្ធផលមុខវិជ្ជាភាសាខ្មែរប្រចាំខែ។

តារាងទី១៖

*ចំនួនគ្រូបង្រៀន និងសិស្ស ដែលត្រូវនឹងជ្រើសរើសធ្វើជាសំណាកក្នុងការសិក្សា*

| ឈ្មោះសាលា | ចំនួន | គ្រូ | ចំនួន | សិស្ស | ចំនួន |
|---|---|---|---|---|---|
| អនុវិទ្យាល័យស្រុក | 1 | មុខវិជ្ជាភាសាខ្មែរ | 1 | ខ្សោយ | 6 |

ចំណាំ៖ អ្នកចូលរួមទាំងអស់មានចំនួន៧នាក់

## ៣.៣ ឧបករណ៍សម្រាប់ការស្រាវជ្រាវ

ការសិក្សានេះ អ្នកស្រាវជ្រាវប្រើប្រាស់ទម្រង់បែបពាក់កណ្ដាលសម្ភាសន៍(semi-structured interview) ជាឧបករណ៍មួយដ៏សំខាន់ក្នុងការប្រមូលទិន្នន័យនៅក្នុងការសិក្សាមួយនេះ ពីព្រោះទម្រង់បែបពាក់កណ្ដាលសម្ភាសន៍ ផ្ដល់នូវឱកាសឱ្យអ្នកស្រាវជ្រាវបានយល់កាន់តែលម្អិតនិងស៊ីជម្រៅទាក់ទងទៅនឹងមូលហេតុដែលបណ្ដាលឱ្យសិស្សខ្សោយក្នុងការអានភាសាខ្មែរនៅកម្រិតថ្នាក់ទី៧នេះ ។ លើសពីនេះទៅទៀតនោះ ទម្រង់បែបពាក់កណ្ដាលសម្ភាសន៍ អនុញ្ញាតឱ្យសិស្សបកស្រាយបានលម្អិតអំពីពត៌មានដែលពាក់ព័ន្ធទៅនឹងមូលហេតុរបស់ពួកគាត់ទៅលើការអានផងដែរ ។ ម្យ៉ាងវិញទៀត អ្នកស្រាវជ្រាវបានធ្វើការសម្ភាសន៍អ្នកចូលរួមជាមួយនឹងការពន្យល់អំពីគោលបំណងនៃការស្រាវជ្រាវ គុណសម្បត្តិនៃការស្រាវជ្រាវ និងការរក្សាការសម្ងាត់ជូនអ្នកចូលរួមទាំងអស់។

## ៣.៤ នីតិវិធីនៃការប្រមូលទិន្នន័យ

អ្នកស្រាវជ្រាវជ្រើសរើសប្រើទម្រង់បែបពាក់កណ្ដាលការសម្ភាសន៍ (semi-structured interview) ជាឧបករណ៍មួយដ៏សំខាន់ក្នុងការប្រមូលទិន្នន័យនៅក្នុងការសិក្សាមួយនេះ និងមានលិខិតអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៃការស្រាវជ្រាវនៅអនុវិទ្យាល័យមួយកន្លែង ដោយលោកនាយកមជ្ឈមណ្ឌលស្រាវជ្រាវគរុកោលស្យជំនាន់ថ្មី។ មុននឹងធ្វើការសម្ភាសន៍ អ្នកស្រាវជ្រាវនឹងប្រាប់ពីវត្ថុបំណងនៃការស្រាវជ្រាវទៅដល់

អ្នកចូលរួមទាំងអស់ឱ្យបានដឹង ព្រមទាំងផ្តល់ដំណឹងជាមុនដល់អ្នកចូលរួមថាសុំអនុញ្ញាតក្នុងការសម្ភាសន៍ដោយប្រើម៉ាស៊ីនថតសម្លេង ហើយរាល់ព័ត៌មានទាំងអស់ដែលពួកគាត់ផ្តល់ជូនឱ្យអ្នកស្រាវជ្រាវនឹងត្រូវបានរក្សាជាការសម្ងាត់។ ក្នុងការសម្ភាសន៍អ្នកស្រាវជ្រាវអាចប្រើពេលពី ៣០ ទៅ ៥០នាទី ចំពោះអ្នកចូលរួមម្នាក់ និងមានការសួរសំណួរបែបប្រដេញចំពោះចំណុចណាដែលចាប់អារម្មណ៍ដើម្បីទទួលបានព័ត៌មានបន្ថែម។

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ បែបគុណវិស័យតម្រូវឱ្យអ្នកស្រាវជ្រាវដឹងច្បាស់ពីរបៀប នៃការស្រង់អត្ថន័យទៅក្នុងការសរសេរឱ្យបានល្អ ទើបអ្នកស្រាវជ្រាវអាចសរសេរចម្លើយស្របទៅនឹងសំណួរស្រាវជ្រាវទៅបាន។ ហើយការរៀបចំទិន្នន័យសម្រាប់វិភាគ តម្រូវឱ្យមានការរៀបចំ ព័ត៌មានឱ្យបានស៊ីជម្រៅ ដែលទិន្នន័យបានមកតម្រូវឱ្យអ្នកស្រាវជ្រាវសរសេរសម្រួលពីភាសានិយាយទៅជាភាសាសរសេរមួយដ៏ត្រឹមត្រូវដើម្បីងាយស្រួលក្នុងការវិភាគ។ បន្ទាប់ពីធ្វើកិច្ចសម្ភាសរួចអ្នកស្រាវជ្រាវត្រូវកត់ត្រារាល់ ពាក្យសំដី ដែលអ្នកចូលរួមបានផ្តល់ឱ្យ ហើយទិន្នន័យ ដែលបានមកនោះអ្នកស្រាវជ្រាវត្រូវមានការគិតខ្ពស់ ដោយប្រុងប្រយ័ត្នដើម្បីវិភាគក្នុងការកំណត់គំនិតសំខាន់ៗ។ ជារួមដំណើរការវិភាគទិន្នន័យ ដំបូង គឺអ្នកស្រាវជ្រាវត្រូវអាននិងសរសេរដោយម៉ត់ចត់។ បន្ទាប់មកទៀត ត្រូវការប្រែសម្រួលលើទិន្នន័យតាមកសិក្សាក្នុងការវិភាគ។ នៅចុងបញ្ចប់ លទ្ធផលត្រូវបានកំណត់សញ្ញាមួយច្បាស់លាស់និងធ្វើចំណែកថ្នាក់តាមគំនិតសំខាន់នីមួយៗ។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ដើម្បីចងក្រងនូវការសិក្សាមួយនេះអោយមានប្រសិទ្ធភាពនិងផលិតភាព អ្នកស្រាវជ្រាវយកចិត្តទុកដាក់ទៅលើការរក្សានូវឯកជនភាព និងការសម្ងាត់អំពីអត្តសញ្ញាណរបស់អ្នកចូលរួម ។ ដូច្នេះនៅក្នុងដំណើរការនៃការចុះប្រមូលទិន្នន័យ ជាដំបូងអ្នកស្រាវជ្រាវបានធ្វើលិខិតស្នើសុំអនុញ្ញាតចុះធ្វើការសិក្សាស្រាវជ្រាវពីលោកនាយកនៃមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី ។ ក្រោយពីទទួលបាននូវការអនុញ្ញាតរួចមក អ្នកស្រាវជ្រាវបានរៀបចំឯកសារមួយទៀតស្នើសុំលោកនាយកនៃសាលា

អនុវិទ្យាល័យមួយ ទទួលបានការអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវនៅទីនោះ ដោយបានជម្រាបជូននូវប្រធានបទនៃការសិក្សាស្រាវជ្រាវ ព្រមទាំងគោលបំណងនៃការស្រាវជ្រាវច្បាស់លាស់ផងដែរ ។ ទន្ទឹមនឹងនេះ អ្នកស្រាវជ្រាវបានរៀបចំលិខិតថ្មីមួយទៀតដើម្បីស្នើសុំការសម្ភាសន៍ជាមួយអ្នកចូលរួម ដោយមានការចុះហត្ថលេខាយល់ព្រមពីសំណាក់អ្នកចូលរួមទាំងអស់ ព្រមទាំងបានជម្រាបជូននូវប្រធានបទនៃការសិក្សាស្រាវជ្រាវ ព្រមទាំងគោលបំណងនៃការស្រាវជ្រាវច្បាស់លាស់ មុននឹងអ្នកស្រាវជ្រាវធ្វើការចុះហត្ថលេខា ។ លើសពីនេះទៅទៀតនោះ អ្នកស្រាវជ្រាវបានធ្វើការណែនាំដល់អ្នកចូលរួមអំពីនីតិវិធីមួយចំនួនក្នុងការឆ្លើយសំណួរ ដោយអ្នកចូលរួមអាចអោយអ្នកស្រាវជ្រាវសួរនូវសំណួរម្តងទៀតករណីអ្នកចូលរួមមិនយល់ឬស្តាប់មិនទាន់ ហើយអ្នកចូលរួមអនុញ្ញាតអោយរំលងមិនឆ្លើយនូវសំណួរណាមួយដែលប៉ះពាល់ដល់អារម្មណ៍ ឬសំណួរដែលអ្នកចូលរួមគិតថាវាជាសំណួរដែលមិនមានសុវត្ថិភាព ឬអ្នកចូលរួមមិនមានទំនុកចិត្តក្នុងការឆ្លើយសំណួរនោះបាន ។ ជាពិសេសទៅទៀតនោះ អត្តសញ្ញាណផ្ទាល់ខ្លួនរបស់អ្នកចូលរួមទាំងអស់ត្រូវបានរក្សាការសម្ងាត់ដោយអ្នកស្រាវជ្រាវផ្ទាល់ ក្នុងនោះឈ្មោះរបស់អ្នកចូលរួម ភេទ រួមទាំងថ្នាក់ដែលគាត់បង្រៀនឬរៀនក៏ត្រូវបានរក្សាការសម្ងាត់ជូនដែរ ប្រសិនបើអ្នកចូលរួមមិនអនុញ្ញាតអោយបង្ហាញ ។ រីឯឯកសារពាក់ព័ន្ធទាក់ទងទៅនឹងព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួមត្រូវបានរក្សាយ៉ាងសម្ងាត់និងមានសុវត្ថិភាពក្នុងប្រព័ន្ធកុំព្យូទ័រ ដោយមានតែអ្នកស្រាវជ្រាវ និងលោកគ្រូណែនាំប៉ុណ្ណោះដែលអនុញ្ញាតឱ្យភ្ជាប់ទៅនឹងទិន្នន័យទាំងអស់នោះបាន និងមិនមានការបញ្ចេញបញ្ចូលព័ត៌មានបន្ថែមឡើយ។ ក្រោយពីការវិភាគទិន្នន័យត្រូវបានបញ្ចប់ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួមទាំងអស់ត្រូវបានលុបចោល ដោយមិនមានការចម្លងទុកនោះទេ ។

## ៣.៧ សេចក្តីសង្ខេបនៃជំពូក

នៅក្នុងការស្រាវជ្រាវនេះប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យ និង កំណត់យកប្រភេទសំណាកគំរូមានគោលបំណងដោយប្រើទម្រង់បែបពាក់កណ្តាលការសម្ភាសន៍។ ការស្រាវជ្រាវនេះជ្រើសរើសគ្រូថ្នាក់ទី៧ ចំនួន ១នាក់ ពីអនុវិទ្យាល័យមួយកន្លែង  សិស្សខ្សោយក្នុងការអានភាសាខ្មែរនៅកម្រិតថ្នាក់ទី ៧ ចំនួន ៦នាក់ ក្នុងចំណោមសិស្សពីរថ្នាក់ ដោយចំនួនកម្រិតថ្នាក់ទី៧ សរុបមាន២ថ្នាក់ ក្នុងមួយថ្នាក់អ្នកស្រាវជ្រាវជ្រើសរើសយកចំនួន ៣នាក់។

# ជំពូក ៤៖ លទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវនឹងពិពណ៌នាអំពីលទ្ធផលនៃការស្រាវជ្រាវ ដែលទទួលបានតាមរយៈវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ការប្រើកិច្ចសម្ភាសន៍បែបពាក់កណ្ដាលគម្រោងទៅលើភាគីពីរដែលចូលរួម។ ជាមួយគ្នានេះ ភាគីទាំងពីររួមមាន អ្នកចូលរួមក្រុមសិស្ស និងអ្នកចូលរួមជាគ្រូ។ ស្របគ្នានេះដែរ អ្នកស្រាវជ្រាវនឹងបែងចែកជាបី ផ្នែកធំៗរួមមាន៖ ១.ព័ត៌មានរបស់អ្នកចូលរួម ២.កត្តាដែលបណ្ដាលឱ្យសិស្សខ្សោយការអាន និង ៣.បញ្ហាដែលសិស្សជួបប្រទះពេលខ្សោយការអាន។ ទន្ទឹមនឹងនេះដែរ នៅក្នុងផ្នែកធំៗខាងលើ អ្នកស្រាវជ្រាវក៏បានបញ្ចូលនៅចំណុចតូចៗលម្អិតនៅក្នុងនោះផងដែរ។

## ៤.១. ព័ត៌មានរបស់អ្នកចូលរួម

នៅផ្នែកទី១នេះ អ្នកស្រាវជ្រាវចង់បង្ហាញអំពីព័ត៌មានទូទៅខ្លះៗរបស់អ្នកចូលរួមដែលមានតួនាទីជាគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ និងសិស្ស។ ស្របតាមក្រមសីលធម៌នៃការស្រាវជ្រាវ អ្នកស្រាវជ្រាវមិនបានបង្ហាញអត្តសញ្ញាណរបស់អ្នកចូលរួមទេ ដោយអ្នកស្រាវជ្រាវបានដាក់ជាលេខកូដសម្គាល់ខ្លួនសម្រាប់អ្នកចូលរួមនីមួយៗ។

តារាងទី២៖

*ព័ត៌មានរបស់អ្នកចូលរួមមានតួនាទីជាគ្រូបង្រៀននិងសិស្ស*

| កូដ | ភេទ | អាយុ | តួនាទី | កម្រិតថ្នាក់ | កម្រិតសមត្ថភាព |
|---|---|---|---|---|---|
| អ្នកគ្រូភាសាខ្មែរ | ស្រី | ២៦ | បង្រៀន | ៧/៨/៩ | |
| ក១ | ស្រី | ១៣ | សិស្ស | ៧ | ខ្សោយ |
| ក២ | ប្រុស | ១២ | សិស្ស | ៧ | ខ្សោយ |
| ក៣ | ប្រុស | ១៤ | សិស្ស | ៧ | ខ្សោយ |
| ក៤ | ស្រី | ១៣ | សិស្ស | ៧ | ខ្សោយ |
| ក៥ | ប្រុស | ១៣ | សិស្ស | ៧ | ខ្សោយ |
| ក៦ | ប្រុស | ១៣ | សិស្ស | ៧ | ខ្សោយ |

ចំណាំ៖ អ្នកចូលរួមជាគ្រូភាសាខ្មែរមានបទពិសោធ៤ឆ្នាំ

### ៤.២. កត្តាដែលបណ្ដាលឱ្យសិស្សខ្សោយការអាន

#### ក. ការយល់ឃើញរបស់គ្រូ

##### ១. កត្តាសុខភាព

តាមរយៈការលើកឡើងរបស់អ្នកចូលរួមជាគ្រូ បានលើកឡើងពីការលំបាករបស់សិស្សក្នុងការអានអត្ថបទភាសាខ្មែរដោយសិស្សមិនទាន់ចេះ ព្យញ្ជនៈ ស្រៈ ពួកអ ពួកអ៊ី បានស្ទាត់និងច្បាស់លាស់។ ម្យ៉ាងវិញទៀត សិស្សមិនអាចបែងចែកដាច់ នូវពួកអ ពួកអ៊ី លើការប្រកបនឹងស្រៈនិស្ស័យ និងការបញ្ចេញសម្លេងបានច្បាស់លាស់នៅឡើយ។ ដូច្នេះហើយអ្វីដែល អ្នកចូលរួមជាគ្រូបានសង្កេតឃើញនៅការលំបាកច្រើនបំផុតរបស់សិស្សតែងជួបប្រទះ គឺបញ្ហាលើការមិនទាន់ចេះព្យញ្ជនៈ និងមិនទាន់ចេះប្រកបដែលជាបញ្ហាប្រឈមបំផុតរបស់គ្រូក្នុងការបង្រៀន និងការរៀនរបស់សិស្ស។ ជាមួយគ្នានេះផងដែរ អ្នកចូលរួមជាគ្រូ ក៏បានលើកឡើងបន្ថែមពីកត្តាដែលនាំឱ្យសិស្សខ្សោយក្នុងការអានផងដែរ ក្នុងនោះកត្តាចំបងគឺទាក់ទងទៅនឹងខាងផ្នែកសុខភាព។ ចំពោះសិស្សដែលខ្សោយការអាន អ្នកចូលរួមជាគ្រូ បានលើកឡើងទៅនឹងបញ្ហាសុខភាព ឬជំងឺរបស់សិស្សជះឥទ្ធិពលទៅលើសមត្ថភាពនៃការអាន និងការចងចាំខ្លាំងបំផុត ដែលក្នុងនោះចំពោះអារម្មណ៍ និងស្មារតីក្នុងការសិក្សា សិស្សដែលខ្សោយការអានពួកគាត់មានការពិបាកក្នុងការផ្ចង់ស្មារតី រយៈពេលក្នុងការផ្ដោតខ្លី មិនមានការចងចាំបានយូរ និងបានច្រើនទាក់ទងនឹងការស្ដាប់ ការសិក្សាក្នុងថ្នាក់ ជាពិសេសសិស្សមិនមានការរំលឹកឡើងវិញពីអ្វីដែលបានរៀននៅក្នុងថ្នាក់។ បន្ថែមពីនេះទៀតនោះ អ្នកចូលរួមជាគ្រូ ក៏បានលើកឡើងថា សិស្សហាក់បីដូចជា មានការភ្លេចភ្លាំងច្រើន ខ្ជិលសារមេរៀន មិនសូវយល់និងចាប់ចំណុចសំខាន់មិនសូវបាន តាមមិនទាន់សិស្សឯទៀត។ ម៉្យាងវិញទៀត ក្នុងការឱ្យដំបូន្មាន ក៏ដូចជាការណែនាំមួយចំនួនក្នុងការសិក្សា សិស្សដែលខ្សោយការអានមិនសូវជាមានការយកចិត្តទុកដាក់ចំពោះពាក្យសម្ដីរបស់គ្រូ និងមិនធ្វើតាមដូចជា ការធ្វើលំហាត់ជាដើម។

##### ២. កត្តាគ្រួសារ (ឪពុកម្ដាយ ឬ អាណាព្យាបាល)

ឆ្លងកាត់ការសម្ភាសន៍ចំពោះអ្នកចូលរួមជាគ្រូ បានលើកឡើងបន្ថែមទាក់ទងនឹងកត្តាដែលនាំឱ្យសិស្សខ្សោយក្នុងការអានថា កត្តាគ្រួសារគឺជាកត្តាដែលសំខាន់និងធំបំផុតរបស់សិស្ស។ ជាក់ស្ដែង អ្នកចូល

រួមជាគ្រូ បានអះអាងថា សិស្សដែលមានបញ្ហាក្នុងការអាន ពុំសូវបានសិក្សាជាប់លាប់ និងមកសាលាបានគ្រប់ពេលនោះទេ ក្នុងនោះមានហេតុផលចម្បងៗមួយចំនួនទាក់ទងនឹងទីកន្លែងដែលសិស្សរស់នៅ គឺនៅទីជនបទ ដែលស្ទើរតែគ្រប់ក្រុមគ្រួសារ ដែលប្រកបរបរកសិកម្ម ដោយការធ្វើស្រែ ចម្ការជាដើម។ យ៉ាងណាមិញ គ្រួសារសិស្សដែលជាឪពុកម្តាយ ឬអាណាព្យាបាលមិនមានពេលគ្រប់គ្រាន់ក្នុងការតាមដានការសិក្សារបស់កូន និងមានការរស់នៅមិនអចិន្ត្រៃយ៍ទើបធ្វើឱ្យពួកគាត់ត្រូវយកកូនទៅតាមការរស់នៅរបស់ខ្លួនដើម្បីជីវភាព។ មួយវិញទៀត អ្នកចូលរួមជាគ្រូបានលើកឡើងថា ឪពុកម្តាយដែលមានទីលំនៅពិតប្រាកដ និងជាប់លាប់ ក៏មានការអាក់ខានកូនក្នុងការសិក្សាផងដែរ ដោយការយកកូនឱ្យទៅជួយធ្វើស្រែ ធ្វើចម្ការជាមួយ ដូចជាការដាំដំឡូង រើសគ្រាប់ចន្ទី។ ក្រៅពីនេះទៀតនោះ ឪពុកម្តាយ ឬអាណាព្យាបាល មិនមានការជម្រុញកូនឱ្យមានសិក្សានៅផ្ទះបន្ថែម ដោយពួកគាត់គិតថាការសិក្សារបស់កូនមានតែនៅសាលា និងរៀនពីគ្រូតែប៉ុណ្ណោះ ហើយអ្វីដែលពិសេសដែលអ្នកចូលរួមជាគ្រូ បានលើកឡើងគឺទាក់ទងទៅនឹងចំណេះដឹងរបស់ឪពុកម្តាយ ឬអាណាព្យាបាលតែម្តង។ ចំណេះដឹងរបស់ពួកគាត់ហាក់នូវមានកម្រិតនៅឡើយ ដែលធ្វើឱ្យពួកគាត់មិនអាចជួយ រឺបង្រៀនបន្ថែមនៅផ្ទះទៅតាមកិច្ចការ និងចម្ងល់របស់កូនខ្លួនបានក្បោះក្បាយ និងត្រឹមត្រូវ។

## ៣. កត្តាបរិយាកាស

ផ្អែកលើការផ្តល់ព័ត៌មានតាមរយៈការសម្ភាសន៍របស់អ្នកចូលរួមជាគ្រូ បានលើកឡើងទាក់ទងទៅនឹងការសិក្សារបស់សិស្សតាំងពីកម្រិតបឋមមក។ ជាការពិតអ្នកចូលរួមជាគ្រូ បានលើកឡើងថាសិស្សមានការលំបាកក្នុងការអាន និងខ្សោយតាំងពីបឋម ហើយម្យ៉ាងវិញទៀតសិស្សមានភាពនឿយណាយក្នុងការសិក្សាដោយមិនមានការតាំងចិត្ត និងជម្រុញពីបរិយាកាសជុំវិញ។ ដោយឡែក អ្នកគ្រូក៏បានបន្ថែមទៀតថា នៅក្នុងថ្នាក់រៀនមិនមានសម្ភារឱ្យសិស្សគ្រប់គ្រាន់ ដូចជាសៀវភៅសិក្សាផ្សេងៗ រឺងបណ្ណាល័យ សម្រាប់សិស្សមធ្យមសិក្សាមិនមានម៉ោងណាមួយដើម្បីដឹកនាំសិស្សចូលបណ្ណាល័យឡើយ ដូច្នេះ សិស្សមិនមានការជម្រុញក្នុងការអាន និងមិនមានតម្រូវការចាំបាច់ក្នុងការរៀនអាន។ ក្នុងនោះអ្នកគ្រូបានលើកឡើងពីបរិបទកូវីត ដោយការរីករាលដាលនៃកូវីត១៩ ធ្វើឱ្យសិស្សទទួលបានការសិក្សា

រៀនសូត្រមិន ពេញលេញ បូករួមទាំងពួកគេខ្សោយមូលដ្ឋានគ្រឹះក្នុងការអានស្រាប់ធ្វើឱ្យលទ្ធផលមាន ការធ្លាក់ចុះ និងកាន់តែកើនឡើងនៃសិស្សខ្សោយការអានច្រើន។

### ខ. ការយល់ឃើញរបស់សិស្ស

យោងតាមចម្លើយរបស់សិស្សដែលបានចូលរួមតាមរយៈការសម្ភាសន៍ទាំងប្រាំមួយនាក់ (ដែលជាសិស្សខ្សោយ) ហាក់បីដូចជាមិនចាកឆ្ងាយពីចម្លើយដែលទទួលបានពីអ្នកចូលរួមជាគ្រូ ទៅលើការលំបាកដែលនាំឱ្យពួកគេខ្សោយក្នុងការអាននោះទេ។ ជាក់ស្តែង ក្នុងចំណោមសិស្សដែលបានចូលរួមការសម្ភាសន៍ទាំងប្រាំមួយនាក់ បានលើកឡើងដូចៗគ្នាថា ទោះបីជាពួកគេមានការលំបាកក្នុងការអានក៏ដោយ ក៏ពួកគេនៅតែចូលចិត្តការអាន ដើម្បីជាការរៀនអាន និងប្រកបពាក្យឱ្យបានកាន់តែស្ទាត់ផងដែរ។ ដោយឡែកចំពោះសមត្ថភាពនៃការអានភាសាខ្មែរ អ្នកចូលរួម (ក១,ក៤,ក៥,ក៦) ក៏បានបន្ថែមដែលថា ពួកគេមានកម្រិតក្នុងការអាន ជាមធ្យម រីឯអ្នកចូលរួម (ក២,ក៣) បានលើកឡើងថាពួកគេមានសមត្ថភាពក្នុងការអានមានកម្រិតខ្សោយនៅឡើយដោយសារ អត់សូវចេះប្រកប អានទាក់ៗ អានពាក្យមិនសូវបាន។ ក្នុងនោះផងដែរ អ្នកចូលរួមដែលមានតួនាទីជាសិស្ស ទាំងអស់បានបន្ថែមដូចគ្នាថា ពួកគេចូលចិត្តអានសៀវភៅរឿង ដើម្បីជាការកំសាន្ត នៅពេលទំនេរពីម៉ោងរៀន ជាមួយមិត្តភក្តិផ្សេងៗទៀត នៅបណ្ណាល័យ ដើម្បីជាការរៀនអានពាក្យផងដែរ។ ដោយឡែក ចំពោះការរៀនមុខវិជ្ជាភាសាខ្មែរ អ្នកចូលរួមជាសិស្ស (ក១) បានលើកឡើងថា ខ្លួនមិនសូវមានការលំបាកទេ ដោយសារតែអាចប្រកបបាន ចំណែកអ្នកចូលរួមជាសិស្ស (ក២,ក៣,ក៤,ក៥,ក៦) លើកឡើងដោយឡែកថាខ្លួនមានការលំបាកខ្លាំងក្នុងការរៀនមុខវិជ្ជាភាសាខ្មែរ ទាក់ទងនឹងការអានជាពិសេស ព្រោះថាមិនសូវចេះអាន ពាក្យមួយចំនួនអានមិនបាន ព្យាង្គ ព្យញ្ជនៈ ស្រៈមិនសូវស្គាល់ និងមិនចេះប្រកប ហើយម្យ៉ាងទៀតមិនសូវយល់កិច្ចការដែលគ្រូបានដាក់ឱ្យ។ ក្នុងនោះផងដែរ អ្នកចូលរួមជាសិស្សទាំងអស់បានលើកឡើងដូចគ្នាថា ការបង្រៀនរបស់គ្រូមិនមានជាបញ្ហាអ្វីចោទនោះទេ ពោលគ្រូៗមានការយកចិត្តទុកដាក់ ព្រួយបារម្ភចំពោះការរៀនរបស់សិស្សខ្លួនជាខ្លាំង ហើយក៏មានជាការពន្យល់យ៉ាងក្បោះក្បាយជាខ្លាំងណាស់ដែរទៅលើការរៀននេះ ជាពិសេសការអាន។ យ៉ាងណាមិញ សិស្សដែលបានចូលរួមការសម្ភាសន៍ចំនួនពីររូប គឺ(ក១និងក៣) បានបង្ហាញពីភាពខុសគ្នាពីការរៀនកាលនៅបឋមនិងពេលចូលរៀននៅអនុវិទ្យាល័យថា ពួកគេខ្វះការយកចិត្តទុកដាក់ក្នុងការ

រៀន មិនខំប្រឹងប្រែងរៀននោះឡើយ ហើយអ្វីដែលពួកគេបន្ថែមគឺខ្វះការជម្រុញពីក្រុមគ្រួសារ ក្នុងការសិក្សាទៀតផង ដោយសមាជិកគ្រួសារជាពិសេសឪពុកម្ដាយ ឬអាណាព្យាបាលមិនបានតាមដានខ្វល់ខ្វាយ និងយកចិត្តទុកដាក់បានគ្រប់ជ្រុងជ្រោយក្នុងការសិក្សារបស់កូន ប៉ុន្តែនៅកម្រិតអនុវិទ្យាល័យ សិស្សបែរជាមានការតាំងចិត្ត និងយកចិត្តទុកដាក់ក្នុងការសិក្សាឡើងវិញ ដោយពួកគេបានបន្ថែមថាមានការជម្រុញនិងលើកទឹកចិត្តពីឪពុកម្ដាយ ឬអាណាព្យាបាលខ្លាំង។ ចំពោះសិស្ស (ក៤,ក៥) បានឆ្លើយថា ការរៀននៅបឋមមានភាពងាយស្រួល និងសិស្ស (ក៦)លើកឡើងថាកាលនៅបឋមរៀនប្រកបអាន ដោយឡែកនៅមធ្យមសិក្សាមានការលំបាក និងមិនរៀនប្រកបពាក្យនីមួយៗឡើយ។ ម្យ៉ាងវិញទៀត នៅកម្រិតបឋមសិក្សាជាកម្រិតមូលដ្ឋានគ្រឹះដែលបានលើកឡើងដោយសិស្ស (ក២) ហើយការរៀនចាប់ផ្ដើមពីមូលដ្ឋានគ្រឹះទៅងាយយល់ ងាយសិក្សាជាងការរៀននៅអនុវិទ្យាល័យដែលមានមុខវិជ្ជាច្រើន និងគ្រូបង្រៀនផ្សេងៗគ្នា។

សរុបមក កម្សោយនៃការអានរបស់សិស្សទាក់ទងខ្លាំងទៅនឹងកត្តាផ្ទាល់ខ្លួនសិស្ស ដូចជាជំងឺប្រចាំកាយពាក់ព័ន្ធនឹងសុខភាពបញ្ញា ក៏ដូចជាមួយចំនួនទៀតគួបផ្សំនឹងគ្រួសារសិស្ស ខ្វះការជម្រុញ ណែនាំ និងបង្រៀនបន្ថែមនៅផ្ទះ ហើយមួយវិញទៀតទាក់ទងនឹងបរិកាសសាលា គ្រូបង្រៀនផ្ទាល់ទៅលើទីកន្លែងរៀន និងវិធីបង្រៀន។

## ៤.៣. បញ្ហាដែលសិស្សជួបប្រទះពេលខ្សោយការអាន

បែបនៃការប្រព្រឹត្តទៅនៅក្នុងការសម្ភាសន៍ដែលអ្នកស្រាវជ្រាវទទួលបានពីអ្នកចូលរួម មានពីរផ្នែក ដោយៈ ផ្នែកទីមួយ ទទួលបានតាមរយៈការឆ្លើយរបស់គ្រូ និង ផ្នែកទីពីរ ទទួលបានតាមរយៈការឆ្លើយរបស់សិស្សទាំងប្រាំមួយនាក់។ នៅខាងក្រោមនេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីសេចក្ដីលម្អិតទាំងពីរផ្នែកដែលទទួលបានពីអ្នកចូលរួម។

### ៤.៣.១ ការលើកឡើងរបស់គ្រូបង្រៀន

ចំពោះបញ្ហាដែលទទួលបានពីគ្រូបង្រៀន បានលើកឡើងយ៉ាងច្បាស់ៗថា សិស្សរបស់អ្នកគ្រូមានបញ្ហាច្រើនដែលពួកគេជួបប្រទះដែលបណ្ដាលមកពីការដែលពួកគេខ្សោយក្នុងការអាន។ ក្នុងនោះ បញ្ហាចំ

បងដែលជួបគឺធ្វើឱ្យការសិក្សារបស់ពួកគេខ្សោយ សិស្សមិនអាចទទួលបានលទ្ធផលល្អបានឡើយ ប្រសិនជាការអានរបស់ពួកគេនៅមានកម្រិត មិនថាជាមួយមុខវិជ្ជាភាសាខ្មែរ ឬមុខវិជ្ជាផ្សេងទៀត ដោយសារ គ្រប់មុខវិជ្ជាត្រូវការ ការអានដើម្បីយល់ន័យ និងខ្លឹមសាររបស់មេរៀនជាចាំបាច់។ ក្នុងនោះផងដែរ អ្នកគ្រូក៏បានបន្ថែមថា សិស្សលែងចង់មករៀន និងរៀន ដែលបណ្តាលមកពីពួកគេមានការខ្មាសអៀន ជាពិសេសមិត្តភក្តិរួមថ្នាក់។ យ៉ាងណាមិញ អ្នកគ្រូបានលើកឡើងទៀតថា សិស្សមួយចំនួនទៀតបោះបង់ចោលការសិក្សា ដោយតាមឪពុកម្តាយទៅធ្វើការជាមួយ ហើយអ្វីដែលរឹតតែពិសេសនោះ សិស្សដែលមានបញ្ហាទៅលើការសិក្សានេះបានជម្រុញឱ្យពួកគេ ទៅស្វែងរកការងារធ្វើផ្សេងៗ ដូចជា ការងាររោងចក្រ ជាដើម។ នេះជាសម្តីរបស់អ្នកចូលរួមជាគ្រូ៖

"រៀនខ្សោយ ហើយលែងចង់រៀន ធម្មតាតែគាត់អត់ចេះហើយម៉ោងនឹងគឺគាត់អត់ចង់រៀនហ្មង គាត់អានអត់បានចឹង សិស្សអត់ចេះមិនប្រាកដថាគាត់អត់ចង់រៀនទេតែដោយសារពេលនៅក្នុងថ្នាក់គាត់អានអត់បាន គាត់ខ្មាសគេ ចឹងដល់ពេល គាត់បោះបង់ការសិក្សាចោល និងឪពុកម្តាយគាត់ផ្លាស់ទីលំនៅច្រើនកន្លែងចឹង កូនចេះតែទៅតាមម៉ែទៅតាមឪចឹងទៅបោះបង់ចោលហ្មងខ្លះ ហើឪពុកម្តាយឱ្យតែកូនអាយុរាងច្រើនតិចគឺជម្រុញឱ្យកូនទៅធ្វើការអស់ហើយ អត់ឱ្យកូនរៀនទេគិតថារៀននឹងអត់បានអីទេ ដឹងរៀនធ្វើអីរៀនអស់តែលុយ ហើយត្រូវគាត់អត់ចេះទៀតចឹងមានតែរោងចក្រវីក៏ឱ្យគាត់ទៅធ្វើការអីផ្សេងៗហើយអត់ឱ្យរៀនទៀតទេ ចុងក្រោយបំផុតមានតែការបោះបង់ការសិក្សាចោលនឹង។"

## ៤.៣.២ ការលើកឡើងរបស់សិស្ស

តាមរយៈការសម្ភាសន៍ជាមួយសិស្សដែលបានចូលរួមទាំងប្រាំមួយនាក់ អ្នកស្រាវជ្រាវទទួលបានទិន្នន័យពីបញ្ហាដែលសិស្សជួបប្រទះប្រហាក់ប្រហែលទៅនឹងចម្លើយដែលទទួលបានពីអ្នកចូលរួមជាគ្រូដែរជាទូទៅ។ ក្នុងនោះ អ្នកចូលរួមជាសិស្សទាំងអស់បានផ្តល់ចម្លើយដូចគ្នាថា ពួកគេជួបប្រទះទៅលើលទ្ធផលនៃការសិក្សាមិនល្អ ធ្លាក់ មិនបានទទួលពិន្ទុល្អ និងលទ្ធផលបានល្អប្រសើរនោះឡើយ។ ហើយបើតាម (ក១,ក២,ក៣)បានលើកឡើងថា ពួកគេទទួលរងនៅអារម្មណ៍អន់ចិត្ត មិនសប្បាយចិត្តពីមិត្តភក្តិ ដែលរងការមើលងាយ និងមិត្តភក្តិស្តីបន្ទោស ថាឱ្យនូវពាក្យសម្តីមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ពួកគេ ដោយមិនមានការជួយប្រាប់រីណែនាំល្អៗពីមិត្តរួមថ្នាក់នោះឡើយ។ យ៉ាងណាមិញ អ្នកចូលរួមជាសិស្ស

ក៥ បានបន្ថែមថាពេលដែលខ្លួនខ្សោយការអានបែបនេះធ្វើឱ្យមិនអាចឆ្លើយនូវអ្វីដែរគ្រូសួរបាន ហើយធ្វើឱ្យមានចិត្តខ្លាចអោសាលា មិនចង់ទៅ ខ្លាចមិត្តភក្តិបង្អាប់ផ្សេងៗ។ ម្យ៉ាងវិញទៀត អ្នកចូលរួមជាសិស្ស (ក៣) បានលើកឡើងថា ខ្លួនពិតជាមានគំនិតបោះបង់ចោលការសិក្សាណាស់ មិនចង់បន្តរៀនទៀតទេ ដោយសារហេតុផលខាងលើប៉ះពាល់ និងបង្អាក់ទៅលើសកម្មភាពរៀនខ្លាំងណាស់។

## ៤.៤ សេចក្តីសង្ខេបនៃជំពូក

សរុបមក បញ្ហាដែលសិស្សជួបប្រទះទាំងអស់ដែលបានរៀបរាប់ខាងលើគឺពាក់ព័ន្ធទៅនឹងអារម្មណ៍ផ្លូវចិត្ត ខ្មាសអៀន អន់ចិត្ត ដែលទទួលរងពីការបង្អាប់ ស្តីបន្ទោសពីមិត្តភក្តិ ជាហេតុធ្វើឱ្យពួកខ្លាចមិនហ៊ានមកសាលា និងឈានដល់ការបោះបង់ការសិក្សាចោល។

# ជំពូកទី៥៖ ការពិភាក្សា

នៅក្នុងជំពូកនេះសរសេរឡើងក្នុងគោលបំណងពិភាក្សាវាងលទ្ធផលដែលការសិក្សានេះរកឃើញជាមួយលទ្ធផលនៃការនៃការសិក្សាផ្សេងទៀតដែលមានបង្ហាញនៅក្នុងជំពូកទី២ ហើយលទ្ធផលនៃការសិក្សាទាំងពីរអាចមានទំនាក់ទំនងគ្នានិងប្លែកគ្នាមួយចំនួនដែរ។ នៅក្នុងលទ្ធផលនៃការសិក្សានេះផងដែរ អ្នកស្រាវជ្រាវបានបែងចែកគំនិតសំខាន់ៗពីរចំណុច គឺកត្តាបណ្ដាលឱ្យសិស្សខ្សោយការអាន និងផលប៉ះពាល់ទៅលើកម្សោយនៃការអាន។

## ៥.១ កត្តាបណ្ដាលឱ្យសិស្សខ្សោយការអាន

នៅក្នុងការស្រាវជ្រាវមួយនេះ បានរកឃើញពីបញ្ហាដែលប្រឈមនៃការអានរបស់សិស្សមួយចំនួនដែលនៅក្នុងនោះរួមមាន៖ បញ្ហាសិស្សខ្លួនឯងពាក់ព័ន្ធនឹងសុខភាព ដោយខ្វះការលើកទឹកចិត្តជម្រុញបន្ថែម បញ្ហាគ្រួសារទាក់ទងនឹងឪពុកម្ដាយ ឬអាណាព្យាបាលដែលពុំសូវមានចំណេះដឹង ជីវភាពខ្វះខាត មិនយកចិត្តទុកដាក់លើការសិក្សារបស់កូន មិនជំរុញលើកទឹកចិត្តដល់កូននៅក្នុងការសិក្សា និងមិនជួយបង្រៀនបន្ថែមដល់កូននៅផ្ទះ បញ្ហាសិស្សខ្វះមូលដ្ឋានគ្រឹះក្នុងការអានតាំងពីបឋមសិក្សាមក។ បញ្ហាទាំងប៉ុន្មានដែលបានរកឃើញខាងលើនេះ មិនខុសប្លែកពីការស្រាវជ្រាវឃើញរបស់លោក Chiu and McBride-Chang (2006, 2010) ទៅលើបញ្ហាជីវភាព សេដ្ឋកិច្ចគ្រួសាររបស់សិស្សមានទំនាក់ទំនងវិជ្ជមានទៅលើការសមិទ្ធផលនៃការអានរបស់ពួកគេ។ យ៉ាងណាមិញ លោក Eurydice; (2011) ក៏បានរកឃើញទាក់ទងនឹងបរិយាកាសមិនល្អ កង្វះការលើកទឹកចិត្តក្នុងការអាន និងយុទ្ធសាស្ត្រក្នុងការអានដ៏មានប្រសិទ្ធភាព ដែលត្រូវទៅនឹងអ្វីដែលអ្នកស្រាវជ្រាវបានរកឃើញដែរ។

យោងតាមការពិភាក្សាខាងលើ សរុបមកកត្តាសេដ្ឋកិច្ចគ្រួសារពិតជាជះឥទ្ធិពលយ៉ាងខ្លាំងដល់សមត្ថភាពនៃការអានរបស់សិស្សពិតប្រាកដមែន។

## ៥.២ ផលប៉ះពាល់ទៅលើកម្សោយនៃការអាន

ទាក់ទងទៅនឹងបញ្ហានេះ ក៏ធ្វើឱ្យសិស្សមានផលប៉ះពាល់មួយចំនួនដោយទទួលរងការគំរាមគំហែងពីមិត្តភក្តិ និងមានអារម្មណ៍ថាអ្នកដ៏ទៃមើលងាយ ស្តីបន្ទោស នេះបើតាមរកឃើញរបស់លោក (Kayabasi, 2017)។ ចំណែកឯការរកឃើញមួយនេះវិញក៏មិនខុសប្លែកគ្នានោះដែល អ្នកស្រាវជ្រាវបានរកឃើញថា សិស្សដែលមានបញ្ហាខ្សោយការអានតែងតែមានអារម្មណ៍អន់ចិត្ត រងការស្តីបន្ទោស ការបង្អាប់ពីមិត្តភក្តិផងដែរ។ ទទឹមនឹងនេះដែល Kayabasi បានលើកឡើងថាសិស្សដែលមានបញ្ហានេះគឺមានសភាពស្ងប់ស្ងាត់ អៀនច្រើន មិនសូវសកម្មក្នុងការសិក្សា និងជៀសវាងអ្វីៗទាំងអស់ដែលទាក់ទងនឹងការអានតាមដែលអាចធ្វើទៅបាន ប៉ុន្តែចំពោះការសិក្សាទៅលើប្រធានបទមួយនេះវិញ អ្នកស្រាវជ្រាវមិនបានទទួលទិន្នន័យពីអ្នកចូលរួមជាសិស្សបានលើកឡើងទៅលើចំណុចនេះឡើយ។

យោងតាមការពិភាក្សាខាងលើ សរុបមកកម្សោយនៃអានពិតជាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្លូវចិត្តរបស់សិស្សក្នុងការសិក្សាខ្លាំងពិតប្រាកដមែន។

## ៥.៣ សេចក្តីសង្ខេបនៃជំពូក

ជារួមការពិភាក្សានេះបានសន្និដ្ឋានថាកត្តាសេដ្ឋកិច្ចគ្រួសារពិតជាជះឥទ្ធិពលយ៉ាងខ្លាំងដល់សមត្ថភាពនៃការអានរបស់សិស្សជាខ្លាំង។ ចំណែកឯ កម្សោយនៃការអានពិតជាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្លូវចិត្តរបស់សិស្សក្នុងការសិក្សាខ្លាំងផងដែរ។

# ជំពូកទី៦៖ សន្និដ្ឋាន ដែនកំណត់ និងសំណូមពរ

វត្ថុបំណងនៃជំពូកទី៦នេះ គឺជាការសំយោគនិងសរុបនូវលទ្ធផលដែលសិក្សាលើកម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ បន្ទាប់ពីធ្វើការបញ្ចប់និងពិភាក្សារួច។ អ្នកស្រាវជ្រាវបានបែងចែកគំនិតសំខាន់សម្រាប់បង្ហាញក្នុងជំពូកនេះជា៣គឺ សេចក្តីសន្និដ្ឋាន ដែនកំណត់នៃការសិក្សាស្រាវជ្រាវ និងសំណូមពរ។

## ៦.១ សេចក្តីសន្និដ្ឋាន

នៅក្នុងផ្នែកនេះ បង្ហាញពីការរកឃើញនូវសំណួរស្រាវជ្រាវទាំង២ ដោយទាក់ទងទៅនឹងកត្តាដែលបណ្តាលឱ្យសិស្សខ្សោយក្នុងការអានភាសាខ្មែរ និងបញ្ហាដែលសិស្សជួបប្រទះនូវការខ្សោយការអានភាសាខ្មែរនេះនៅថ្នាក់ទី៧នៅសាលាអនុវិទ្យាល័យមួយ។ ម៉្យាងទៀត ការសិក្សាមួយនេះធ្វើឡើងដោយមានការចូលរួមពី សិស្សខ្សោយ៦នាក់ និងគ្រូបង្រៀនភាសាខ្មែរ១នាក់ ដែលសរុបទាំងអស់៧នាក់។ បន្ថែមពីនេះទៅទៀត ការសិក្សានេះធ្វើឡើងតាមវិធីសាស្ត្រគុណវិស័យដោយប្រើនូវទម្រង់បែបពាក់កណ្តាលការសម្ភាសន៍ (semi-structured interview) ដែលមានសំណួរទាំងអស់ជាសំណួរបើក។ តាមរយៈទិន្នន័យដែលទទួលបាន និងធ្វើការវិភាគរួចមក យើងឃើញថាសមត្ថភាពរបស់សិស្សនៅថ្នាក់ទី៧នៅសាលាអនុវិទ្យាល័យនៅមានកម្រិតនៅឡើយ។ ចំពោះសំណួរស្រាវជ្រាវទី១ បានរកឃើញថា កត្តាដែលបណ្តាលឱ្យសិស្សខ្សោយក្នុងការអាន អ្នកស្រាវជ្រាវបានរកឃើញ៣កត្តាធំៗ (១). កត្តាសុខភាព សិស្សពិបាកក្នុងការផ្ចង់ស្មារតី រយៈពេលក្នុងការផ្តោតខ្លី មិនមានការចងចាំបានយូរ មានការភ្លេចភ្លាំងច្រើន (២). កត្តាគ្រួសារ ខ្វះការយកចិត្តទុកដាក់ មិនមានការជម្រុញកូនឱ្យមានសិក្សានៅផ្ទះបន្ថែម ចំណេះដឹងរបស់ពួកគាត់ហាក់នូវមានកម្រិតនៅឡើយដែលធ្វើឱ្យពួកគាត់មិនអាចជួយ ឬបង្រៀនកូនបានគ្រប់ជ្រុងជ្រោយ (៣). កត្តាបរិយាកាស ដោយការរីករាលដាលនៃកូវីត១៩ ធ្វើឱ្យសិស្សទទួលបានការសិក្សារៀនសូត្រមិនពេញលេញ បូករួមទាំងពួកគេខ្សោយមូលដ្ឋានគ្រឹះក្នុងការអានស្រាប់ធ្វើឱ្យលទ្ធផលមានការធ្លាក់ចុះ និងកាន់តែកើនឡើងនៃសិស្សខ្សោយការអានច្រើន នៅក្នុងថ្នាក់រៀនមិនមានសម្ភារឱ្យសិស្សគ្រប់គ្រាន់ ដូចជាសៀវភៅសិក្សាផ្សេងៗ រីឯបណ្ណាល័យ សម្រាប់សិស្សមធ្យមសិក្សាមិនមានម៉ោងណាមួយដើម្បីដឹកនាំសិស្ស

ចូលបណ្ណាល័យ បញ្ហាសិស្សខ្សោយតាំងពីបឋម ហើយម៉្យាងវិញទៀតសិស្សមានភាពនឿយណាយក្នុងការសិក្សាដោយមិនមានការតាំងចិត្ត និងជម្រុញពីបរិយាកាសជុំវិញ។ ចំណែកឯ ការស្រាវជ្រាវទៅលើសំណួរទី២បានរកឃើញថា សិស្សជួបប្រទះបញ្ហាមួយចំនួនដែលបណ្តាលមកពីកម្សោយនៃការអាន លទ្ធផលនៃការសិក្សាមិនល្អ ធ្លាក់ មានការខ្មាសអៀន ទទួលរងនូវពាក្យសម្តីមួយចំនួនដែលធ្វើឱ្យប៉ះពាល់ដល់ផ្លូវចិត្តរបស់ពួកគេ មានចិត្តខ្លាចអោសាលា ខ្លាចមិត្តកក្តិបង្អាប់ សិស្សលែងចង់មករៀន មានគំនិតបោះបង់ចោលការសិក្សា។

## ៦.២ វិសាលភាព និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះ គឺមានដែនកំណត់របស់វា ដែលដូចអ្វីដែលបានបង្ហាញនិងពន្យល់ខាងដើមតែប៉ុណ្ណោះ។ អ្នកស្រាវជ្រាវក្នុងការសិក្សានេះ គឺមានបទពិសោធថ្មីថ្មោងក្នុងការសិក្សាស្រាវជ្រាវមួយនេះ។ សម្រាប់ហេតុផលនេះ អ្នកស្រាវជ្រាវអាចនឹងមានការវិភាគ ពិចារណានៅមិនទាន់គ្រប់ជ្រុងជ្រោយនៃបញ្ហា ហើយក៏អាចនាំអ្នកអានឬអ្នកស្រាវជ្រាវផ្សេងទៀតទៅដល់ចំណេះដឹងមួយដែលមានបញ្ហាដោយអចេតនា។

តាមរយៈលក្ខណៈស្រាវជ្រាវមួយនេះ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្របែបគុណវិស័យដែលរុករកអំពីកត្តារបស់សិស្សថ្នាក់ទី៧ដែលខ្សោយក្នុងការអាន និងបញ្ហាដែលសិស្សបានជួបប្រទះនៅពេលខ្សោយក្នុងការអានភាសាខ្មែរ ដោយមានការចូលរួមពីគ្រូ និងសិស្សតែប៉ុណ្ណោះ។ ដូច្នេះការសិក្សាមួយនេះច្បាស់ណាស់ថានឹងមានការខ្វះចន្លោះ ខ្លឹមសារ មួយចំនួនជាក់ជាមិនខាន។ បន្ថែមពីនេះទៅទៀត ការស្រាវជ្រាវមួយនេះ មានអ្នកចូលរួមទាំងអស់តែ៧នាក់តែប៉ុណ្ណោះ ក្នុងនោះមានគ្រូ១នាក់ និងសិស្សខ្សោយ៦នាក់។ ចំពោះសិស្សខ្សោយ អ្នកស្រាវជ្រាវជ្រើសរើសដោយការសាកសួរពីគ្រូបន្ទុកថ្នាក់ផ្ទាល់  ចំណែកឯវត្ថុបំណងនៃការស្រាវជ្រាវមួយនេះផ្តោតលើកត្តាដែលនាំឱ្យសិស្សខ្សោយក្នុងការអាន និងបញ្ហាដែលសិស្សនឹងជួបប្រទះពេលដែលខ្សោយការអាននៅអនុវិទ្យាល័យមួយតែប៉ុណ្ណោះ មិនមានវិសាលភាពកំណត់បានទូលំទូលាយទូទាំងប្រទេស និងគ្រប់សាលានោះឡើយ។

សរុបមក ការស្រាវជ្រាវមួយនេះ មានពេលវេលាកំណត់និងឯកសារនៅមានកម្រិត ហើយអ្នកស្រាវជ្រាវធ្វើការសិក្សានេះដើម្បីតែបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់របស់ខ្លួនដោយមានការជួយពីគ្រូដឹកនាំតែម្នាក់ប៉ុណ្ណោះ ហេតុនេះកំហុសដែលកើតមានឡើងដោយអចេតនាជៀសមិនផុតឡើយ។

## ៦.៣ សំណូមពរ

ចំពោះលទ្ធផលដែលបានរកឃើញ តាមរយៈការសិក្សានេះ បានបង្ហាញពីកត្តាដែលបណ្តាលឱ្យសិស្សខ្សោយការអាន និងបញ្ហាដែលសិស្សជួបប្រទះដែលបណ្តាលមកពីកម្សោយការអានរបស់សិស្សថ្នាក់ទី៧។ អក្ខរកម្មភាសាខ្មែរពិតជាសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋខ្មែរទាំងអស់ ជាពិសេសសិស្សានុសិស្សដែលជាទំពាំងស្នងឫស្សី ជាអ្នកបន្តវេនជំនាន់ក្រោយ ដូច្នេះវាជាការចាំបាច់ណាស់ដែលសិស្សានុសិស្សត្រូវចេះអានភាសាខ្មែរជាតិរបស់ខ្លួន។ ឆ្លើយតបទៅនឹងបញ្ហា ដែលបានលើកឡើងខាងលើនៃការស្រាវជ្រាវមួយនេះ នឹងផ្តល់នូវសំណូមពរមួយចំនួនផងដែរដើម្បីជាការស្ថាបនា បំពេញបន្ថែម និងជាគំនិតយកទៅអនុវត្តក្នុងការដោះស្រាយបញ្ហានានាដែលអាចលេចឡើងក្នុងការសិក្សារបស់សិស្ស ឱ្យកាន់តែប្រសើរឡើង។

### ៦.៣.១ ចំពោះគ្រូបង្រៀន

ការអប់រំដែលមានគុណភាព អាស្រ័យលើគុណភាពគ្រូនៅក្នុងការបង្រៀននៅតាមសាលា ដូច្នេះការលើកទឹកចិត្តគ្រូ ការបណ្តុះបណ្តាលគ្រូទាក់ទងនឹងវិធីសាស្ត្រជាពិសេសទៅលើការអាន ក៏ដូចជាការវាយតម្លៃគ្រូជាប្រចាំ ជាការប្រសើរដើម្បីឱ្យគ្រូបានឆ្លុះបញ្ចាំងពីស្ថានភាពរបស់ខ្លួន និងកែលំអនូវចំណុចខ្វះខាតបានជាប្រចាំ។ យ៉ាងណាមិញ ក្រសួង អប់រំ យុវជន និងកីឡា គួរមានជារង្វាន់លើកទឹកចិត្តគ្រូដែលល្អឬគ្រូឆ្នើមប្រចាំឆ្នាំ ដើម្បីបង្ហាញថាពេលដែលគ្រូមានការខិតខំប្រឹងប្រែង មានអ្នកមើលឃើញ មានអ្នកទទួលស្គាល់ ដែលជាកំលាំងចិត្តមួយជួយជម្រុញដល់គ្រូមានការស្រាវជ្រាវ រុករកអ្វីដែលថ្មី យកមកបង្ហាត់បង្ហាញ និងបង្រៀនសិស្សរបស់ខ្លួនអស់ពីកំលាំងកាយចិត្ត។ មួយវិញទៀត ការដែលមានគ្រូល្អឬឆ្នើមជាប្រចាំ នឹងជាចំណែកចូលរួមជួយទៅកាន់លើកកម្ពស់គុណភាពគ្រូបានល្អប្រសើរឡើង។

### ៦.៣.២ អាណាព្យាបាល

គន្លងមក យើងសង្កេតឃើញថាសិស្សមានការសិក្សានៅមានកម្រិតបណ្តាលមកពីខ្វះការចូលរួមមួយផ្នែករបស់អាណាព្យាបាលឬឪពុកម្តាយ។ ជាការពិត កុមារទាំងអស់ត្រូវទទួលបានការសិក្សាគ្រប់ៗគ្នានៅក្នុងសាលាជាមួយគ្រូ ដោយឡែកអាណាព្យាបាលក៏ជាធាតុផ្សំយ៉ាងសំខាន់សម្រាប់សិស្សទាំងអស់ដែលជាកូនៗរបស់ពួកគាត់នៅក្នុងការអប់រំបន្ថែមនៅផ្ទះដូចគ្នា។ អាណាព្យាបាល ឬឪពុកម្តាយគប្បីតាមដានការ

សិក្សារបស់កូនជាប្រចាំ ដើម្បីបង្ហាញនូវការយកចិត្តទុកដាក់ ក្នុងនាមជាឪពុកម្តាយ លើការសិក្សារបស់ពួកគេ។ សូមមេត្តាបន្តការគាំទ្រឱ្យពួកគាត់ខិតខំរៀនសូត្របន្ត តាមរយៈការលើកទឹកចិត្ត ផ្តល់ពេលវេលាក្នុងការសិក្សានៅផ្ទះ និងគាំទ្រពីក្រោយជានិច្ច បើទោះជាលទ្ធផលបែបណាក៏ដោយ វានឹងមានល្អប្រសើរជាងមុន កូនចៅនឹងមានភាពកក់ក្តៅ ឱ្យតម្លៃលើការសិក្សា និងមានភាពប្រឹងប្រែងខិតខំរៀនជាប្រចាំ។

### ៦.៣.៣ ចំពោះសាលា ឬគណៈគ្រប់គ្រង

នៅតាមសាលា គួរមានការរៀបចំនិងលើកទឹកចិត្តដល់សិស្សក្នុងការអាន ជាពិសេសបណ្ណាល័យត្រូវរៀបចំគួរជាទីពេញចិត្តនិងចាប់អារម្មណ៍ដល់សិស្សដោយមានសៀវភៅគ្រប់ប្រភេទគ្រប់កម្រិតថ្នាក់សម្រាប់សិស្សក្នុងការអាន។ មួយវិញទៀត តាមសាលាគួរមានទីធ្លាសម្រាប់សិស្សអានឱ្យបានសមរម្យ និងមានពេលវេលាគ្រប់គ្រាន់សម្រាប់ឱ្យសិស្សអាន។ បន្ថែមពីនេះទៀតសាលាអាចមានជាកម្មវិធីប្រកួតប្រជែងអានដើម្បីជាការជំរុញនិងលើកទឹកចិត្តដល់សិស្សបន្ថែម។

### ៦.៣.៤ ការសិក្សាស្រាវជ្រាវបន្ត

ការសិក្សាលើប្រធានបទកម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលា អនុវិទ្យាល័យមួយកន្លែង ចំពោះសិស្សថ្នាក់ទី៧ នៃសាលាអនុវិទ្យាល័យមួយក្នុង ស្រុកកំពង់សៀម ខេត្តកំពង់ចាម តែប៉ុណ្ណោះ មិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមិនមានលក្ខណៈទូទៅនោះឡើយ។ ការស្រាវជ្រាវនេះគ្រាន់តែចង់បង្ហាញពីកត្តាដែលបណ្តាលឱ្យសិស្សខ្សោយការអាន និងបញ្ហាដែលសិស្សជួបប្រទះដែលបណ្តាលមកពីការខ្សោយការអានភាសាខ្មែរតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ អ្នកសិក្សាបន្ទាប់អាចសិក្សាឱ្យបានស៊ីជម្រៅជាងនេះបន្ថែមទៀត ទៅលើបញ្ហាប្រឈម និងវិធីសាស្ត្រដែលចូលរួមជួយដោះស្រាយបញ្ហាកម្សោយការអាន ដើម្បីកែលំអប្រព័ន្ធអប់រំនៅកម្ពុជា។

## ៦.៤ សេចក្តីសង្ខេបនៃជំពូក

នៅក្នុងជំពូកនេះ បានលើកឡើងទាក់ទងនឹងការសន្និដ្ឋាននៃការស្រាវជ្រាវ ដែលបានរកឃើញពីកត្តាធំៗ៣គឺ (១). កត្តាសុខភាព សិស្សពិបាកក្នុងការផ្ចង់ស្មារតី រយៈពេលក្នុងការផ្តោតខ្លី មិនមានការចងចាំបានយូរ មានការភ្លេចភ្លាំងច្រើន (២). កត្តាគ្រួសារ ខ្វះការយកចិត្តទុកដាក់ មិនមានការជម្រុញកូនឱ្យ

មានសិក្សានៅផ្ទះបន្ថែម ចំណេះដឹងរបស់ពួកគាត់ហាក់នូវមានកម្រិតនៅឡើយដែលធ្វើឱ្យពួកគាត់មិនអាចជួយ ឬបង្រៀនកូនបានគ្រប់ជ្រុងជ្រោយ (៣). កត្តាបរិយាកាស បរិបទកូវីតសិស្សមិនបានរៀនពេញលេញ។ យ៉ាងណាមិញ ការស្រាវជ្រាវនេះធ្វើឡើងចំពោះតែសាលាអនុវិទ្យាល័យមួយកន្លែងក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាមតែប៉ុណ្ណោះ មិនមានវិសាលភាពគ្របដណ្តប់គ្រប់សាលាទូទាំងប្រទេសនោះឡើយ។ ម៉្យាងវិញទៀត អ្នកស្រាវជ្រាវក៏មានជា សំណូមពរដល់ គ្រូបង្រៀន គណៈគ្រប់គ្រង អាណាព្យាបាល និងអ្នកស្រាវជ្រាវក្រោយៗទៀតផង។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (២០២០). *ឯកសារជំនួយ ការបង្រៀននិងរៀនសរសេរតាមអានសម្រាប់មធ្យមសិក្សាបឋមភូមិ.* ក្រសួងអប់រំ យុវជន និងកីឡា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). *ស្តង់ដារអំណានថ្នាក់ទី១-៣.* ក្រសួងអប់រំ យុវជន និងកីឡា.

World Bank Group. (2016). ការអានសៀវភៅនៅក្នុងប្រទេសកម្ពុជាកំពុងមានការកើនឡើង. World Bank. https://www.worldbank.org/km/results/2016/09/08/raising-reading-scores

ឡាំ. (២០១៩). *អំណានជាអំណាច* (*E-book*).

https://www.scribd.com/document/485226487/%E1%9E%A2%E1%9F%86%E1%9E%8E%E1%9E%B6%E1%9E%93%E1%9E%87%E1%9E%B6%E1%9E%A2%E1%9F%86%E1%9E%8E%E1%9E%B6%E1%9E%85-pdf

Akyol, H. (2003). *Turkce ilkokuma yazma ogretimi* [Teaching first reading and writing in Turkish]. Ankara, Turkey: Gunduz Egitim.

Akyol, H., & Boyaci-Altinay, Y. (2019). Reading Difficulty and its Remediation: A Case Study. *European Journal of Educational Research*, *8*(4), 1269-1286. https://doi.org/10.12973/eu-jer.8.4.1269

Anderson, R.C., Hiebert, E.H., Scot, J.A., & Wilkinson, Ian A.G. (1985). *Becoming a Nation of Readers: The Report of the Commission on Reading.* Washington, D.C.

Garcia,Y.P., Ramayan, A.J.R. Sepe, A.P. & Silor, A.C. (2014). Difficulties in Reading Comprehension and Metacognitive Strategies for Technology Livelihood Education Students. *Proceeding at the Global Summit on Education GSE 2014* (E-ISBN978-967-11768-5-6)

Kayabasi, Z. E. K. (2017). Views of Classroom Teachers Concerning Students with Reading Difficulties. *International Journal of Progressive Education*, *13*(3), 50-60.

MoEYS (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development*. Phnom Penh: Author.

Rahmat,N.H., Syed Abdul Rahman,S.A., and Hassan,H.R. (2018) Exploring Reading Issues among Millennials and GenZ. *European Journal of English Language*

*Teaching. 4*(2), pp 112-125. Retrieved from https://oapub.org/edu/index.php/ejel/article/view/2158

Rahmat, N. H., Arepin, M., & Sulaiman, S. (2020b). The Cycle of Academic Reading Fear Among Undergraduates. *Asian Journal of University Education*, *16*(3), 265. https://doi.org/10.24191/ajue.v16i3.9730

Specktor, B. (2018). Here's Why Your Brain Needs You to Read Every Single Day. *Reader's Digest.* Retrieved August 28, 2018, from https://www.rd.com/culture/benefits-of-reading/

Therrien, W. J. (2004). Fluency and Comprehension Gains as a Result of Repeated Reading. *Remedial and Special Education*, *25*(4), 252–261. https://doi.org/10.1177/07419325040250040801

Zehra Esra Ketenoglu, K. (2017). Views of classroom teachers concerning students with reading difficulties. *International Journal of Progressive Education*, *13*(3), 50–60.

# ពិធីសារសម្ភាសន៍

## ប្រធានបទ៖ កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យស្រុក

- ម៉ោងនៃការសម្ភាស៖…………………………………………
- កាលបរិច្ឆេទ៖…………………………………………………..
- ទីកន្លែង៖…………………………………………………………
- អ្នកសម្ភាស៖…………………………………………………..
- អ្នកផ្តល់កិច្ចសម្ភាស៖…………………………………………..
- តួនាទីរបស់អ្នកផ្តល់កិច្ចសម្ភាស៖…………………………..

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យ ឃើញពីកត្តាទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី ៧នៃអនុវិទ្យាល័យ ស្រុក ព្រម ទាំងបញ្ហាដែលសិស្សជួបប្រទះពេលខ្សោយការអានភាសាខ្មែរ។ ចំពោះព័ត៌មានដែល បានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី ៤០នាទី នោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយអ្នកស្រាវជ្រាវសុំឱ្យអ្នកផ្តល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- **ចាប់ផ្តើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖**

| ល.រ | **សំណួរសម្រាប់សម្ភាសន៍គ្រូ** |
|---|---|
| ១ | តើអ្នកគ្រូបង្រៀនភាសាខ្មែរថ្នាក់ទី៧បានរយៈពេលប៉ុន្មានឆ្នាំហើយ ? |
| ២ | តើសិស្សរបស់អ្នកគ្រូមានការលំបាកក្នុងការអានអត្ថបទជាភាសាខ្មែរដែរឬទេ ? |
| ៣ | តើអ្វីជាការលំបាកក្នុងការអានច្រើនបំផុតដែលអ្នកគ្រូបានសង្កេតឃើញចំពោះសិស្សរបស់អ្នកគ្រូ ? |
| ៤ | តើកត្តាអ្វីខ្លះដែរអ្នកគ្រូយល់ថា ជាផ្នែកមួយដែលបណ្តាលឱ្យសិស្សខ្សោយក្នុងការអានអត្ថបទជាភាសាខ្មែរ ?( ឧ. គ្រួសារ បរិយាកាសសាលា...)។ |
| ៥ | តើបញ្ហាសុខភាពរឺជំងឺរបស់សិស្សជះឥទ្ធិពលទៅលើសមត្ថភាពនៃការអាន និងការចងចាំរបស់ពួកគេដែររឺទេ ?( ជំងឺខ្សោយការចងចាំ, ជំងឺដែលពិបាកនឹងចុះសម្រុងនឹងអ្នកដ៏ទៃ, ជំងឺខ្សោយការផ្ចង់អារម្មណ៍...) ? |
| ៦ | តើសិស្សរបស់អ្នកគ្រូជួបប្រទះបញ្ហាអ្វីខ្លះ នៅពេលដែលពួកគេមានការលំបាកក្នុងការអាន ? |
| ៧ | តើអ្វីខ្លះជាឧបសគ្គដែលនាំឱ្យអ្នកគ្រូពិបាកក្នុងការបង្រៀនមុខវិជ្ជាភាសាខ្មែរដល់សិស្សខ្សោយទាំងនោះ ? |

# ពិធីសារសម្ភាសន៍

## ប្រធានបទ៖ កម្សោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យស្រុក

- ម៉ោងនៃការសម្ភាស៖……………………………………………
- កាលបរិច្ឆេទ៖……………………………………………………
- ទីកន្លែង៖…………………………………………………………
- អ្នកសម្ភាស៖……………………………………………………
- អ្នកផ្តល់កិច្ចសម្ភាស៖……………………………………………
- តួនាទីរបស់អ្នកផ្តល់កិច្ចសម្ភាស៖……………………………

វត្ថុបំណងនៃការសម្ភាសនិងការសិក្សាលើប្រធានបទនេះគឺអ្នកស្រាវជ្រាវមានបំណងរកឱ្យ ឃើញពីកត្តាទាំងឡាយដែលនាំឱ្យសិស្សខ្សោយការអានភាសាខ្មែរនៅថ្នាក់ទី ៧នៃអនុវិទ្យាល័យ ស្រុក ព្រម ទាំងបញ្ហាដែលសិស្សជួបប្រទះពេលខ្សោយការអានភាសាខ្មែរ។ ចំពោះព័ត៌មានដែល បានមកពីអ្នកចូលរួមម្នាក់ៗត្រូវប្រមូលមកទុកជាទិន្នន័យដើម្បីវិភាគ ហើយទិន្នន័យដែលបានមកទាំងអស់ អ្នកស្រាវជ្រាវនឹងរក្សាវាជាការសម្ងាត់។ ជាមួយគ្នានេះ រយៈពេលនៃការសម្ភាសគឺមិនឱ្យលើសពី ៤០នាទី នោះទេ បន្ទាប់មកអ្នកស្រាវជ្រាវក៏សុំការអនុញ្ញាតថតសំឡេងនៅកំឡុងពេលសម្ភាសនោះផងដែរ ពីព្រោះការពារការកត់ត្រាមានចន្លោះខ្វះខាត។ ហើយជាចុងក្រោយអ្នកស្រាវជ្រាវសុំឱ្យអ្នកផ្តល់កិច្ចសម្ភាសអាននូវកំណត់ត្រាសម្ភាសនិងចុះហត្ថលេខាយល់ព្រមផងដែរ។

- **ចាប់ផ្តើមសាកល្បងម៉ាស៊ីនថតសំឡេង រួចថត៖**

| ល.រ | **សំណួរសម្រាប់សម្ភាសន៍សិស្ស** |
|---|---|
| ១ | តើប្អូនចូលចិត្តការអានភាសាខ្មែរដែរឬទេ?<br>១.១ បើប្អូនមិនចូលចិត្ត តើមានមូលហេតុអ្វីខ្លះ?<br>១.២ បើប្អូនចូលចិត្ត តើប្រភេទឯកសារណាខ្លះដែលប្អូនធ្លាប់បានអាន?<br>១.៣ ជាទូទៅប្អូនអាននៅពេលណា ហើយក្នុងគោលបំណងអ្វី? |
| ២ | តើប្អូនគិតថាសមត្ថភាពនៃការអានភាសាខ្មែររបស់ប្អូននៅកម្រិតណា?(ល្អ ល្អបង្គួរ មធ្យម ខ្សោយ ខ្សោយណាស់) |
| ៣ | ៣.១ តើការរៀនមុខវិជ្ជាភាសាខ្មែរមានការលំបាកសម្រាប់ប្អូនដែរឬទេ? ហេតុអ្វី?<br>៣.២ តើប្អូនពេញចិត្តទៅនឹងវិធីសាស្ត្របង្រៀនអំណានរបស់គ្រូប្អូនដែរឬទេ? បើពេញចិត្ត ហេតុអ្វី(សួរពីចំណុចដែលពួកគេពេញចិត្តជាក់លាក់) បើមិនពេញចិត្ត ហេតុអ្វី (សួរតី ចំណុចដែលពួកគេមិនពេញចិត្តជាក់លាក់)។<br>៣.៣ តើការរៀនអំណាននៅបឋមសិក្សានិងអនុវិទ្យាល័យខុសគ្នាដូចម្តេចខ្លះ? |
| ៤ | តើប្អូនមានការលំបាកអ្វីខ្លះក្នុងការអាន?(ឧ.មិនចេះពាក្យ មិនយល់ពីអត្ថន័យ ពិបាកក្នុងការ |

| | |
|---|---|
| | ផ្ទង់អារម្មណ៍ ) |
| ៥ | នៅពេលដែលប្អូនជួបការលំបាក ដូចដែរបានរៀបរាប់ខាងលើ តើវានឹងបង្កឱ្យមានបញ្ហាអ្វីផ្សេងទៀតសម្រាប់ការសិក្សារបស់ប្អូន ? |

( សូមអរគុណដល់អ្នកចូលរួមនិងការសហការ ក្នុងការសម្ភាសន៍នេះ។ សូមជានាចំពោះអ្នកចូលរួមថានឹងរក្សាការសម្ងាត់នៃការឆ្លើយតបនិងបន្តសក្តានុពលសម្រាប់ការសម្ភាសន៍នាពេលអនាគត។ )

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
3

មជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី
NEW GENERATION PEDAGOGICAL RESEARCH CENTER

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២២

**សូមគោរពជូន**

**លោក ធន់ គីមអេង នាយកសាលាបឋមសិក្សានិងអនុវិទ្យាល័យស្រក**

**កម្មវត្ថុះ** សំណើសុំការអនុញ្ញាតឱ្យគរុនិស្សិតឈ្មោះ **រឹម ស្រីវ៉ៃ** បានចុះប្រមូលទិន្នន័យស្រាវជ្រាវលើប្រធានបទ " **កម្រោយនៃការអានភាសាខ្មែររបស់សិស្សថ្នាក់ទី៧ នៅសាលាអនុវិទ្យាល័យស្រក**" ក្នុងចន្លោះថ្ងៃទី១០ ខែមិថុនា ដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

សេចក្តីដូចបានជម្រាបក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាបជូន លោកនាយកឱ្យបានជ្រាបថា លោកស្រី **រឹម ស្រីវ៉ៃ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ឯកទេសប្រឹក្សាគរុកោសល្យ ជំនាន់ទី៣ សិក្សានៅមជ្ឈមណ្ឌលស្រាវជ្រាវគរុកោសល្យជំនាន់ថ្មី នៃវិទ្យាស្ថានជាតិអប់រំ។ លោកស្រីមានគម្រោងចុះសិក្សាស្រាវជ្រាវក៏ដូចជាប្រមូលទិន្នន័យ ដើម្បីសរសេរសារណាខ្លីក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់អប់រំ។ គោលបំណងនៃការចុះប្រមូលទិន្នន័យនេះ គឺដើម្បីប្រមូលព័ត៌មានសំខាន់ៗ ដែលទាក់ទងទៅនឹងប្រធានបទស្រាវជ្រាវខាងលើ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវ មួយនេះ នឹងអាចចូលរួមចំណែកក្នុង ការជំរុញ និងលើកកម្ពស់ឱ្យការបង្រៀន និងរៀន ភាសាខ្មែរនៅកម្រិតអនុវិទ្យាល័យកាន់តែមានភាពល្អប្រសើរឡើងផងដែរ។

អាស្រ័យហេតុនេះ សូមលោកនាយកមេត្តាអនុញ្ញាត និងជួយសម្រួលដល់គរុនិស្សិតរូបនេះ បានចុះប្រមូលទិន្នន័យតាមការស្នើសុំដូចបានជម្រាបក្នុងកម្មវត្ថុខាងលើដោយក្តីអនុគ្រោះ។

សូមលោកនាយកទទួលនូវការគោរពរាប់អានដ៏ស្មោះអំពីខ្ញុំ

**ប្រធានមជ្ឈមណ្ឌល**

បណ្ឌិតសភាចារ្យ **ច័ន្ទ រ័ត្ន**

ឯកសារ មសគថ.

# Empowering educators with ethical and evidence-based practices




Email: ngprc.faculty@gmail.com
Website: www.ngprc.edu.kh